**មជ្ឈមណ្ឌលដើម្បី សន្តិភាព និង អភិវឌ្ឍន៍**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំ ខប់សែលប្រ៉័មតំបន់ទី ៥

# យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

**ថ្ងៃអង្គារ ទី១៥ ខែសីហា ឆ្នាំ២០០៦**

**ក្រុង ប៉ៃលិន**

**ខប់សែល ដំណាក់កាលទី ២**
COPCEL Phase II

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

**របៀបវារៈ**

១. ចំណាប់អារម្មណ៍ស្វាគមន៍ ដោយលោក **ឡារី ស្ត្រេន្ទ** នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

២. បទអន្តរាគមន៍ស្ដីពីយន្តការឧប់សែលប្រ៉ម (COPCELPROM) ដោយលោក **ឱក សេរី សោភក្តិ** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការ ឧប់សែល នៃវិទ្យាស្ថាន CDRI

៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោកស្រី អៀង សូភី ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតក្រុងប៉ៃលិន

៤. មតិរបស់អ្នកចូលរួមដែលបង្ហាញពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតនៅក្នុងបរិបទក្រុងប៉ៃលិន

៥. សេចក្ដីផ្សេងៗ

---

**លោក ឡារី ស្ត្រេន្ទ ជានាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្ដុះបណ្ដាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍** (CDRI ) លោកបានជម្រាបជូនថា ហេតុអ្វីបានជាវិទ្យាស្ថាន CDRI រៀបចំកម្មវិធីឧប់សែល ហើយជាពិសេសឧប់សែលនៅថ្នាក់ខេត្តយើងនេះ។ វិទ្យាស្ថាន CDRI ជាវិទ្យាស្ថានមួយធ្វើការស្រាវជ្រាវដោយឯករាជ្យទៅលើគោលនយោបាយ ដើម្បីរៀបចំគោលនយោបាយសម្រាប់រៀបចំការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជាដែលវិទ្យាស្ថាន CDRI មានមូលដ្ឋាននៅទីក្រុងភ្នំពេញ។ វិទ្យាស្ថាន CDRI បានធ្វើការសិក្សាស្រាវជ្រាវទៅលើវិស័យ៥ដែលជាវិស័យសំខាន់ៗនៅក្នុងការអភិវឌ្ឍន៍នឹងធ្វើអោយមានភាពរីកចំរើននៅប្រទេសកម្ពុជា។ វិស័យដែលខាង CDRI បានសិក្សាស្រាវជ្រាវមានដូចជា ផ្នែកខាងអភិវឌ្ឍន៍ សេដ្ឋកិច្ច ពាណិជ្ជកម្ម ជាពិសេសពាណិជ្ជកម្មនៅក្នុងតំបន់ ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍កសិកម្ម ហើយនឹងការបង្កើននៃមុខរបរការចិញ្ចឹមជីវិត ការអភិបាលកិច្ចប្រកបដោយលទ្ធិប្រជាធិតេយ្យ និងកំណែទំរង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ហើយនិងចំនុចចុងក្រោយគឺសន្តិសុខរបស់មនុស្សនិងការកសាងសន្តិភាពនិងការដោះស្រាយទំនាស់។ នៅក្នុងវិស័យទាំងអស់នេះ វិទ្យាស្ថាន CDRI បានធ្វើការយ៉ាងជិតស្និតជាមួយគ្រប់ភាគីពាក់ព័ន្ធនៅក្រុងព្រះរាជាណាចក្រកម្ពុជាយើងនេះ។ ជាពិសេសភាគីពាក់ព័ន្ធដែលជាដៃគូរបស់វិទ្យាស្ថាន CDRI មានដូចជារាជរដ្ឋាភិបាល ខាងស្ថាប័ននានាជុំវិញការងារអភិវឌ្ឍន៍ ខាងសង្គមស៊ីវិល ខាងស្ថាប័នឯកជន ក៏ដូចជាស្ថាប័នជាតិនិងអន្តរជាតិផ្សេងៗផងដែរ។ វិទ្យាស្ថាន CDRI គឺធ្វើការនៅក្នុងក្របខ័ណ្ឌមួយឯករាជ្យនិង អព្យាក្រឹត្យហើយអ្វីដែល វិទ្យាស្ថាន CDRI បានជឿជាក់នៅក្នុងបេសកម្មរបស់ខ្លួននោះគឺការអភិវឌ្ឍន៍នានាទាំងឡាយអាចប្រព្រឹត្តិទៅបាន លុះណាតែយើងមានការកសាងសន្តិភាព និងការអភិបាលកិច្ចប្រកបដោយលទ្ធិប្រជាធិតេយ្យដែលជាក្បាលម៉ាស៊ីនមួយដ៏សំខាន់ ក្នុងការឈានទៅរកការអភិវឌ្ឍន៍។ វិទ្យាស្ថាន CDRI យល់ថាការរៀបចំការបោះឆ្នោតដោយរលូនត្រឹមត្រូវនិងយុត្តិធម៌និងមានប្រសិទ្ធភាពគឺជាយន្តការមួយឆ្ពោះទៅរកការកសាងនូវលទ្ធិប្រជាធិតេយ្យមួយដ៏ពិតប្រាកដដែលលទ្ធិប្រជាធិតេយ្យអាចជាក្បាលម៉ាស៊ីនមួយឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបទៅដោយស្ថេរភាព។ ដោយផ្អែកទៅលើទស្សនៈនេះហើយបានជា វិទ្យាស្ថាន CDRI បានរៀបចំនូវកម្មវិធីកិច្ចប្រជុំឧប់សែលទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ខេត្ត ជាពិសេសទាំងនៅថ្នាក់មូលដ្ឋាន ហើយដែល អស់លោក លោក ស្រីចូលរួមនៅពេលនេះគឺកិច្ចប្រជុំថ្នាក់ខេត្តក្រុង។ យើងគិតថាការដែលផ្ដល់ឱកាសជូនចំពោះភាគីពាក់ព័ន្ធនានាជាពិសេសភាគីភាគីពាក់ព័ន្ធជុំវិញរឿងបោះឆ្នោតនេះ ដើម្បីមានឱកាសលើកយកបញ្ហានានា ឬការប្រឈមមុខនានា យកមកពិភាក្សានៅចំពោះមុខគ្នា ដោយត្រង់ទៅត្រង់មកដោយបើកចំហរ នេះជាចំនុចមួយដ៏មានសារៈសំខាន់។ កម្មវិធីរបស់វិទ្យាស្ថាន CDRI ទាំងអស់គឺទទួលបានការគ្រាំទ្រយ៉ាងពេញទំហឹង និងយ៉ាងខ្លាំងពីសំណាក់រដ្ឋាភិបាល ជាពិសេសក្រសួងមហាផ្ទៃ ពីសំណាក់អាជ្ញាធរខេត្តក្រុង និងជាពិសេសពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលយើងហៅថា គជប ហើយដែល

នៅក្នុងពេលនេះលោកក៏សូមឆ្លៀតឱកាសនេះថ្លែងអំណរគុណឯកឧត្តម ម៉ៃ ណាត់ ដែលឯកឧត្តម បានឆ្លៀតឱកាសដ៏មានតម្លៃចូលរួមនៅក្នុងកិច្ចប្រជុំខប់សែលប្រ៉មនៅក្នុងក្រុងប៉ៃលិនយើងនេះ ហើយជាពិសេសសូមថ្លែងនូវអំណរគុណឯកឧត្តមអភិបាលក្រុងដែលបានអោយវិទ្យាស្ថាន CDRI រៀបចំកិច្ចប្រជុំខប់សែលនៅក្នុងថ្ងៃនេះនៅក្រុងប៉ៃលិន។ វិទ្យាស្ថាន CDRI បានចាត់ទុកថាវាជារឿងមានសារៈសំខាន់ណាស់ ខប់សែល ព្រោះធ្វើការដើម្បីគោលបំណងក្នុងការកសាងនូវវប្បធម៌ នៃការពិភាក្សាគ្នានៅចំពោះមុខដោយត្រង់ៗនេះដែលជាមូលដ្ឋានមួយគ្រឹះនៅក្នុងជំរុញអោយមានសន្តិភាព។ ក៏ប៉ុន្តែការជោគជ័យទាំងឡាយនៅក្នុងការជជែកពិភាក្សាគ្នានៅក្នុងខប់សែលនេះគឺ អស់លោក លោកស្រី ដែលចូលរួមយ៉ាងសស្រាក់សស្រាំនៅក្នុង ពេលនេះដែលយើងមានបញ្ហាប្រឈមមុខអ្វីផ្សេងៗទៀត។

**លោក ឱក សេរី សោភក្តិ** លោកក៏បានថ្លែងនូវអំណរគុណ ចំពោះ លោក ឡារី ស្រេន្ទ ដែលលោកមានប្រសាសន៍យ៉ាងក្បោះក្បាយហើយមានអត្ថន័យយ៉ាងជ្រាលជ្រៅចំពោះយន្តការខប់សែលនេះ។

**ឯកឧត្តម ម៉ៃ មគ្គ អភិបាលរងក្រុងប៉ៃលិន** ឯកឧត្តមបានមានប្រសាសន៍ទាក់ទងទៅនឹងការប្រជុំប្រកបដោយវិជ្ជមានក្នុងការអភិវឌ្ឍន៍ធនធានមនុស្សលើការបង្កើតចំណេះដឹង លើការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សំរាប់ការបោះឆ្នោត។ លោកបានចាត់ទុកថាថ្ងៃនេះគឺជាថ្ងៃលើកទឹកចិត្តដល់អ្នកក្រុងប៉ៃលិន ដែលកំពុងស្រលាញ់ពេញចិត្តដែលកំពុងតែអនុវត្តលទ្ធិប្រជាធិបតេយ្យដែលគ្រប់ស្ថាប័ននៅក្នុងក្រុង ទាំងស៊ីវិល ទាំងប្រដាប់អាវុធ កំពុងតែអនុវត្តនូវការរៀបចំការបោះឆ្នោត និងការបោះឆ្នោតធំៗដែលបានធ្វើទៅហើយចំនួន៣លើកនៅប៉ៃលិន គឺនៅថ្ងៃទី២៦ខែកក្កដា១៩៩៨ ហើយឆ្នាំ១៩៩៣យើងមិនបានធ្វើទេ គឺមានការបោះឆ្នោតនៅខែមិថុនា ១៩៩៣យើង ព្រោះថាពេលនោះយើងមិនទាន់បានផ្តាច់ខ្លួនចេញពីនយោបាយរបស់ប៉ុលពតនៅឡើយ ហើយពេលដែលផ្តាច់ខ្លួននៅឆ្នាំ១៩៩៦វាហួសពេលទៅហើយ ដូច្នេះយើងបានធ្វើការបោះឆ្នោតលើកទី១ នៅ ថ្ងៃទី២៦ខែកក្កដាឆ្នាំ១៩៩៨ ហើយបានរួមចំណែកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាសង្កាត់នៅថ្ងៃទី៣ខែកុម្ភៈឆ្នាំ២០០២ និងបានធ្វើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅថ្ងៃទី២៧ខែកក្កដាឆ្នាំ២០០៣។

សមិទ្ធិផលដែលទទួលបាននៅក្នុងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យទាំង៣លើកនេះ គឺពិតជាបានរួមចំណែកយ៉ាងសកម្មដល់ ទី១ អនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលមានសម្តេច ហ៊ុន សែន ជាប្រមុខ។ ទី២ ពង្រឹងនូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការពង្រឹងសិទ្ធមនុស្សនៅប៉ៃលិន។ ទី៣ ពង្រឹងបាននូវសុខសន្តិភាពក្នុងសង្គមជាតិដែលយើងទាំងអស់គ្នាចង់បានជាទីបំផុត។ឯកឧត្តមបានមានប្រសាសន៍ថា ការប្រជុំខប់សែលប្រ៉មនេះ ធ្វើអោយអង្គប្រជុំទាំងអស់គ្នាខិតខំរិះរកអោយឃើញនូវភាពបង្ការទំនាស់ទាំងឡាយនៅក្នុងការបោះឆ្នោតនៅក្នុងក្រុងរបស់យើង ដើម្បីយើងទាំងអស់គ្នារួមចំណែកផ្តល់អនុសាសន៍សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាសង្កាត់ អាណត្តិទី២នៅថ្ងៃទី១ខែមេសាឆ្នាំ២០០៧ប្រកបដោយ ជោគជ័យ។

ឯកឧត្តមសង្ឃឹមថាអនុសាសន៍របស់វាគ្មិនទាំងអស់នឹងធ្វើអោយកុលបុត្រកុលធិតាកម្ពុជាយើងខិតខំឡើង ដើម្បីឆ្លើយតបនឹងសំណូមពររបស់រាជរដ្ឋាភិបាលដែលចង់បាននូវការពង្រឹងសន្តិភាព ការអភិវឌ្ឍន៍ប្រទេស ការផ្លាស់ប្តូរអំណាចអ្នកដឹកនាំតាមរយៈលទ្ធិប្រជាធិបតេយ្យដ៏សុក្រឹតអាស្រ័យទៅលើការបោះឆ្នោតនេះ។ ឯកឧត្តមក៏បានមានប្រសាសន៍ដែរថា ដើម្បីអោយលទ្ធិប្រជាធិបតេយ្យកាន់តែរឹងមាំគឺត្រូវធ្វើអោយប្រជាពលរដ្ឋកាន់តែមានអំណាចក្នុងការជ្រើសរើសអ្នកដឹកនាំដោយសន្តិវិធី ដោយអាស្រ័យទៅលើការបោះឆ្នោតនេះ។ ឯកឧត្តមក៏សង្ឃឹមយ៉ាងមុតមាំថា យើងទាំងអស់គ្នាប្រាកដជាធ្វើជាម្ចាស់នៃអ្នកកាន់លទ្ធិប្រជាធិបតេយ្យគ្រប់គ្នា យើងទាំងអស់គ្នាប្រាកដជារៀនសូត្របាននូវនីតិវិធីគ្រប់យ៉ាង សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាសង្កាត់ ក៏ដូចជាជ្រើសរើសតំណាងរាស្ត្រនៅថ្ងៃ ខាងមុខទៀត។

**លោកឌិក សេរី សោភក្តិ** លោកបានជម្រាបត្រួសៗថា តើយន្តការ ឧប់ សែល នេះកើតឡើងដូចម៉េច ? ហើយពីពេលណាមក ? លោកបានជម្រាបថា លោកបានធ្វើការតស៊ូនៅជាយដែន នៅពេលនោះហើយដែលឃើញថាការដែលធ្វើសង្គ្រាមនេះគឺមិនមានន័យអីទាល់តែសោះ។ ដល់ពេលដែលចប់សង្គាមទៅរាជរដ្ឋាភិបាលពេលនោះឯកឧត្តម ស ខេង ជាមួយនិង សម្តេច ហ៊ុន សែន គឺថាបានជួបគ្នាធ្វើការពិភាក្សា ហើយលោកក៏សុខចិត្តធ្វើជាទីប្រឹក្សា និងនាយកខុទ្ទកាល័យរបស់ឧបនាយករដ្ឋមន្ត្រី ហើយដែលកាលនោះជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម ស ខេង នោះ៥ឆ្នាំ ពីឆ្នាំ១៩៩៣ដល់ឆ្នាំ១៩៩៨។ ហើយឆ្នាំ១៩៩៤ លោកក៏បានគិតពិចារណាដើម្បីធ្វើយ៉ាងណាអោយប្រជាធិតេយ្យចុះមកដល់ថ្នាក់មូលដ្ឋាន ការរីកចំរើនចុះមកដល់មូលដ្ឋានតាមរយៈការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ដែលពេលនោះយើងគិតថានឹងធ្វើនៅឆ្នាំ ២០០០ ដល់ក្រោយមកយឺតពេលទៅ បានរុញមកដល់ ២០០២ ប៉ុន្តែនៅពេលដែលធ្វើការ៥ឆ្នាំជាមួយរាជរដ្ឋាភិបាលហ្នឹង លោកបានគិតហើយថា តើហេតុអីបានជាសង្គ្រាមនៅស្រុកយើងមានដល់ទៅ២៨ឆ្នាំ ? ភាពខ្លោចផ្សា និរាសព្រាត់ព្រាស់មិនចេះចប់មិនចេះហើយ។ នៅពេលដែលចេញពីរាជរដ្ឋាភិបាល៥ឆ្នាំហើយ លោកក៏បានមកធ្វើការនៅវិទ្យាស្ថាន CDRI នេះ ជាអ្នកសំរបសំរួលខាងកម្មវិធីអភិវឌ្ឍន៍ និងសន្តិភាព នៅឆ្នាំ១៩៩៩រហូតដល់ឆ្នាំ២០០៣ គឺនៅពេលនោះហើយដែលវិទ្យាស្ថាន CDRI បានបានធ្វើការស្រាវជ្រាវមួយ ស្តីពីទំនាស់ដែលកើតឡើងនៅក្នុងការបោះឆ្នោតនៅកម្ពុជា។ ហើយលោកក៏បាននឹកឃើញថា ដើម្បីអោយការបោះឆ្នោតនេះលែងមានទំនាស់ទៀត លោកបានគិតថាអកប្បកិយា និងវប្បធម៌របស់ខ្មែរយើងមិនសូវចូលចិត្តនិយាយគ្នាត្រង់ទៅត្រង់មក មិនចូលចិត្តយកបញ្ហាដែលជាទំនាស់ហ្នឹងយកមកដាក់លើតុ ដើម្បីនិយាយគ្នាទេ។ យើងចូលចិត្តញញឹមដាក់គ្នានៅនិងមុខ ប៉ុន្តែក្រោយខ្នងយើងចូលចិត្តនិយាយដើមគ្នាណាស់។ លោកគិតថាការធ្វើដូច្នេះ នាំអោយមានការយល់ច្រឡំច្រើន នាំអោយមានទំនាស់កាន់តែច្រើន ដូច្នេះហើយបានជាលោកចេះតែស្រម័យថា ចង់ឃើញយន្តការមួយជាពិសេសនៅជុំវិញការបោះឆ្នោតហ្នឹងដែរ តួអង្គទាំងអស់ ទាំងគណបក្សនយោបាយ ទាំងអង្គការសង្គមស៊ីវិល ទាំង គជប ទាំងរាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន អង្គុយនៅជុំវិញតុហើយលើកនូវបញ្ហាអ្វីដែលស្តាប់គ្នាមិនបានយកមកដាក់ហើយជជែកគ្នាត្រង់ទៅត្រង់មក ដើម្បីបណ្តុះនូវវប្បធម៌ជជែកពិភាក្សាគ្នាត្រង់ទៅត្រង់មក។ ការពិភាក្សានេះហើយដែលនាំអោយយើងទុកចិត្តគ្នាបាន ព្រោះជួនកាលយើងមិនបានជជែកគ្នាយើងចេះតែចោទគ្នាទៅវិញទៅមក ដល់ពេលដែលយើងជជែកគ្នាទៅ ទោះបីជាយើងមិនស្រុះស្រួលគ្នាមែន តែយើងចាប់ផ្តើមយល់ថា ហេតុអីបានម្នាក់ទៀតគេមានយោលបល់ខុសពីយើង ? ពេលនោះហើយដែលយើងចាប់ផ្តើមគោរពភាពខុសគ្នានៃការយល់ឃើញរបស់យើងម្នាក់ៗ ហើយយើងក៏ចាប់ផ្តើមទុកចិត្តគ្នាថា ការខុសគ្នាមិនមែននាំទៅរកជំលោះទេ ការខុសគ្នានេះហើយដែលនាំអោយយើងកាន់តែយល់ចិត្តគ្នាឡើង អោយសង្គមរបស់យើងកាន់តែជឿនលើនឡើង បានជាមានយន្តការ ឧប់សែល នេះឡើង។ ឧប់សែល នេះ កាលពីមុនក៏មិនចង់ហៅពាក្យអង់គ្លេសដែរ ដែលហៅមកថា Conflic Prevention in Commune Elections យន្តការបង្ការទំនាស់នៅក្នុងការបោះឆ្នោតឃុំសង្កាត់ ប៉ុន្តែដល់ជោគជ័យពេកទៅនៅក្នុងការបោះឆ្នោតជាតិឆ្នាំ២០០៣នោះ ក៏អង្គប្រជុំទាំងអស់សម្រេចអោយបន្តទៅទៀត ដូច្នេះហើយបានជាពាក្យកាត់ ឧប់សែល នេះចាំគ្រប់គ្នាទៅ។ ហើយយន្តការឧប់សែលដំណាក់កាលទី១ បានចប់នៅខែកញ្ញា ឆ្នាំ២០០៣។ លោកក៏មានមោទនភាពដែរ ព្រោះយន្តការនេះ គឺបង្កើតឡើងដោយដៃខ្មែរខ្លួនឯង ប៉ុន្តែនៅឆ្នាំ២០០៤នោះ ដោយសារ UNDP ជាពិសេសលោក Douglas Gardner នោះខាងអង្គការសហប្រជាជាតិនៅញ៉ូយ៉កគាត់បានឃើញសេចក្តីរាយការណ៍ហ្នឹង គាត់ក៏បានមកជួបជាមួយលោក ឡារី ស្រ្តេន្ទ ហើយនិងរូបលោក គាត់ថាយន្តការនេះល្អណាស់ ដែលខ្មែរយើងបង្កើតដោយខ្លួនឯង ហើយមិនដែលឃើញប្រទេសណាដែលទើបនឹងចេញពីសង្គ្រាម ហើយអាចរកយន្តការមួយនិយាយស្តាប់គ្នាបានតាំងពីថ្នាក់លើ ដល់ថ្នាក់ក្រោមបានទេ។ បានជាគាត់សុំអោយវិទ្យាស្ថាន CDRI ហើយនិងរូបលោកធ្វើបន្តទៅទៀត ដើម្បីបំរើការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ដែលនឹងរៀបចំឡើងនូវថ្ងៃទី១ខែមេសាឆ្នាំ២០០៧ខាងមុខនេះ ហើយនឹងការបោះឆ្នោតថ្នាក់ជាតិនៅប្រហែលជាខែកក្កដាឆ្នាំ២០០៨។

យើងខ្ញុំក៏ធ្វើការស្រាវជ្រាវខ្លះ ហើយក៏សុខចិត្ត ប៉ុន្តែម្តងនេះកាលដំណាក់កាលទី១ យើងមិនបានចុះមកធ្វើនៅខេត្តទេ ៤ឆ្នាំយើងប្រជុំគ្នា ៥០ដងរាល់ខែមិនដែលខានទេ ប៉ុន្តែយើងធ្វើតែនៅថ្នាក់ជាតិទេ។ ដល់កាលដំណាក់កាលទី២នេះ ខ្ញុំបាទគិតថាទំនាស់ដែលកើតឡើងពិតប្រាកដក្នុងយន្តការបោះឆ្នោតនៅកម្ពុជាគឺកើតឡើងនៅថ្នាក់ការិយាល័យបោះឆ្នោត កើតឡើងនៅពេលយុទ្ធនាការឃោសនាបោះឆ្នោត កើតឡើងនៅពេលចុះបញ្ជីបោះឆ្នោត កើតឡើងនៅពេលដែលត្រៀមលក្ខណៈធ្វើអត្តសញ្ញាណប័ណ្ណជាតិ កើតឡើងទាំងអស់គឺនៅមូលដ្ឋាន ដូច្នេះមិនគួរដាក់យន្តការឧបសែល នៅតែថ្នាក់ជាតិទេ ត្រូវរុញបញ្ចុះមកនៅថ្នាក់ខេត្ត ជាពិសេសដើម្បីអញ្ជើញក្រុមប្រឹក្សាឃុំសង្កាត់ហ្នឹងអោយលោកបានមកចូលរួមបានមកមានប្រសាសន៍នៅក្នុងហ្នឹង អញ្ចឹងហើយបានជាស្រម័យឃើញថា ឧបសែលប្រ៉ម នេះបានកើតឡើង។ យើងបានទៅធ្វើនៅតាមខេត្តនានាហើយ កំពត តាកែវ កណ្តាល កំពង់សោម កំពង់ស្ពឺ មណ្ឌលគីរី រតនគីរី ស្ទឹងត្រែង រួចហើយបន្តិចទៀតយើងទៅធ្វើនៅខាងកើតទៀត ដូច្នេះយើងដើរធ្វើអញ្ចឹងទាំងអស់ហើយថ្ងៃនេះយើងបានមកធ្វើនៅទីក្រុងប៉ៃលិន។ នៅក្នុងកាលដំណាក់កាលទី២នេះ យើងធ្វើមានគោលដៅធំ៧៣ កាលដែលធ្វើនេះ ធម្មតាទំនាស់កើតឡើងនៅគ្រប់ដំណាក់កាលទាំងអស់តាំងពីចុះឈ្មោះបោះឆ្នោត ឃោសនាបោះឆ្នោត ថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផល។ ប៉ុន្តែមូលហេតុធំ៧មានតែ៣ទេ តាមដែលខ្ញុំមើលទៅ

ទី១ គឺការចុះឈ្មោះបោះឆ្នោត គឺធ្វើយ៉ាងណាអោយគ្រប់គ្នាដែលដល់អាយុបោះឆ្នោតមានសិទ្ធ បានសេចក្តីថាសិទ្ធជាប្រជាពលរដ្ឋជាអ្នកបោះឆ្នោតហើយអ្នកទាំងអស់នោះអាចបោះឆ្នោតបានទាល់តែគាត់មានឈ្មោះគាត់នៅក្នុងបញ្ជីឈ្មោះបោះឆ្នោត។ ដូច្នេះយន្តការនៃការចុះឈ្មោះបោះឆ្នោតនេះត្រូវតែធ្វើទៅអោយបានល្អ។ ហើយយើងក៏សសើរ គជប ណាស់ដែលលោករៀបចំអោយមាន៩ខែជាលក្ខណៈត្រៀមការចុះឈ្មោះបោះឆ្នោតពីខែមករាដល់ខែកញ្ញា ហើយពីខែតុលាយើងចុះឈ្មោះមែនទែន ដូច្នេះធ្វើយ៉ាងណាអោយប្រជាពលរដ្ឋដែលដល់អាយុបោះឆ្នោតបានមានឈ្មោះទាំងអស់គ្នា ហើយឈ្មោះនោះកុំអោយខុសទៀត ព្រោះប្រជាពលរដ្ឋខ្មែរយើងចូលចិត្តដូរឈ្មោះដោយសារយើងទើបនិងចេញពីសង្គ្រាមយើងដាក់ឈ្មោះនេះហើយ រួចហើយយើងត្រឡប់ទៅដូរឈ្មោះនោះវិញ ឬមួយយើងសរសេរឈ្មោះយើងអញ្ចេះដល់ចុះមែនទែនសសេរអញ្ចុះ គឺវង្វេងលេខាធិការដ្ឋានរៀបចំការបោះឆ្នោតថ្នាក់ខេត្តក្រុង ជាពិសេសភូមិភាគឥសានខ្ញុំបាទទៅគឺវង្វេងបញ្ជីឈ្មោះបោះឆ្នោតគឺខុសត្រឡប់ត្រឡឹង។

ដូច្នេះហើយបានឈានទៅដល់ ចំនុចទី២នោះគឺថា អត្តសញ្ញាណប័ណ្ណជាតិ។ ប្រជាពលរដ្ឋដែលកើតឡើងត្រូវតែមានអត្តសញ្ញាណប័ណ្ណជាតិ បើមិនអញ្ចឹងយើងមិនដឹងខ្លួនយើងជាអ្នកណា កើតនៅកន្លែងណា ឃុំណា ស្នាក់នៅឯណា អញ្ចឹងហើយបានជាអត្តសញ្ញាណប័ណ្ណជាតិនេះនឹងក្លាយទៅជាឯកសារ គោលសំរាប់ប្រើប្រាស់នៅក្នុងការបោះឆ្នោត ។

គោលដៅទី៣ គឺធ្វើយ៉ាងណាធានាសន្តិសុខ ដូចឯកឧត្តម ម៉ៃ ណាត់ មានប្រសាសន៍អញ្ចឹង គឺអោយប្រជាពលរដ្ឋជ្រើសរើសអ្នកដឹកនាំរបស់ខ្លួនដោយសន្តិវិធីនៅក្នុងបរិយាកាសសន្តិភាពគ្មានការភ័យខ្លាច នេះជាគោលដៅសំខាន់ណាស់។ កាលណាយើងជជែកគ្នាទៅមកអស់ហើយ យើងយល់គ្នាច្បាស់លាស់អស់ហើយ យើងត្រូវតែត្រៀមលក្ខណៈចូលធ្វើការបោះឆ្នោតដណ្តើមសំលេងឆ្នោតពីប្រជាពលរដ្ឋដោយសន្តិវិធី ប្រសាសន៍របស់ឯកឧត្តមគឺថ្លៃថ្លាណាស់ អញ្ចឹងហើយបានយន្តការ ឧបសែល ចុះមកដល់នេះ ហើយយើងចង់ស្តាប់មតិរបស់វាគ្មិនទាំងអស់ដើម្បីចង់ដឹងថា តើនៅទីក្រុងប៉ៃលិននេះបញ្ហាដែលយើងកំពុងតែប្រឈម ហើយនៅតែប្រឈមនៅឡើយមានបញ្ហាអ្វីខ្លះ ? ហើយតើយើងរួមគ្នាឈានទៅរកដំណោះស្រាយបានយ៉ាងដូចម្តេចខ្លះ ? កន្លែងណាដែលដោះស្រាយមិនបានប្រឹងដោះស្រាយតទៅទៀត ព្រោះយន្តការបោះឆ្នោតប្រើពេលយូរណាស់យើងមិនអាចធ្វើឡើង១ឆ្នាំ ២ឆ្នាំបានទេ ឯកឧត្តមមានប្រសាសន៍ហើយសន្តិភាពពិតប្រាកដគឺក្រោយ១៩៩៨ទេ។

**លោកស្រី អៀង សូភី ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតក្រុងប៉ៃលិន** លោកស្រីបានជម្រាបត្រួស១ពីសកម្មភាពរួមហើយលោកស្រីសង្ឃឹមថាអង្គប្រជុំនឹងចូលរួមជួយផ្តល់មតិនៅលើការរៀបចំអនុសាសន៍ផ្សេង១ច្រើនជាង។ លោកស្រីបានជម្រាបថាក្រុងប៉ៃលិនមានប្រវត្តិសង្គ្រាមរយៈពេលយូរជិត៣ទសវត្សហើយ ហើយសង្គ្រាមដ៏យូរលង់នេះបានបន្សល់ទុកនូវការវិនាសខូចខាតដល់ទឹកដីក្រុងប៉ៃលិន គ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះនៅសេសសល់ពាសពេញដី ហើយសង្គ្រាមនេះបានបន្សល់ទុកផងដែរនូវស្មារតីភ័យខ្លាចទុក្ខព្រួយនិងកង្វល់ដក់ជាប់ក្នុងអារម្មណ៏របស់ប្រជាពលរដ្ឋជាប្រចាំ។ ក្រោយចប់សង្គ្រាមនៅឆ្នាំ១៩៩៨ ទឹកដីក្រុងប៉ៃលិនក៏បានរៀបចំទៅជាក្រុងទី៤របស់ប្រទេសកម្ពុជា លោកស្រីក៏បានជម្រាបជូនដែរថា ក្រុងប៉ៃលិនមានផ្ទៃដីសរុបចំនួនតែ១០៩៧.៦៦គីឡូម៉ែត្រការេបើប្រៀបធៀបទៅនិងខេត្តក្រុងដទៃទៀតទឹកដីនេះវាមិនធំទេ ប៉ុន្តែក្នុងនេះគ្រាន់តែមានមីនមានដល់២៥៦.១៦គីឡូម៉ែត្រការេទៅហើយដូច្នេះឃើញថាទឹកដីដែលប្រជាជនអាចរស់នៅបានមានទំហំតូច ហើយមីនក៏នៅសេសសល់ច្រើនដែរ។ ក្រុងប៉ៃលិនចែកចេញជា២ខ័ណ្ឌគឺខ័ណ្ឌប៉ៃលិនមាន៤សង្កាត់និង៣៦ភូមិ ខ័ណ្ឌសាលាក្រៅមាន៤សង្កាត់និងភូមិចំនួន៤៣ដែលទទួលស្គាល់ជាផ្លូវការពីក្រសួងមហាផ្ទៃ។ លក្ខណៈពិសេសរបស់ក្រុងប៉ៃលិនគឺការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ មានលក្ខណៈប្រមូលផ្តុំនៅតាមទីប្រជុំជនតិចតួចណាស់ក្រៅពីនេះប្រជាជនប្រមាណ៨០ភាគរយគាត់ច្រើនតែរស់នៅមានលក្ខណៈពង្រាយតាមចំការដែលនៅដាច់ស្រយាលពីគ្នា។ ក្រុងប៉ៃលិនបានចូលរួមការបោះឆ្នោតចំនួន៣លើកមកហើយ ដូចឯកឧត្តម ម៉ៃ ណាត បានមានប្រសាសន៏រួចមកហើយគឺថា នៅឆ្នាំ១៩៩៨ ជាការបោះឆ្នោតលើកទី១ ការចូលរួមការបោះឆ្នោតនៅឆ្នាំ១៩៩៨នេះ គឺជាការឈានចូលទៅក្នុងដំណាក់កាលថ្មីនៅក្នុងការចាប់អនុវត្តលទ្ធិប្រជាធិតេយ្យសំរាប់ប្រជាពលរដ្ឋនៅក្រុងប៉ៃលិន។ ហើយលោកស្រីជឿថា វាជារូបមន្តនិងជាជំរើសតែមួយគត់ដើម្បីការផ្សះផ្សារជាតិនិងឯកភាពជាតិយើង។ ក្រុងប៉ៃលិនបានចូលរួមនៅក្នុងការបោះឆ្នោតចំនួន៤លើកហើយ បើយើងរាប់ទាំងការបោះឆ្នោតព្រឹទ្ធសភាផងហើយពីការបោះឆ្នោតមួយទៅកាន់ការបោះឆ្នោតមួយ ជាការសង្កេតឃើញរបស់លេខាធិការដ្ឋានរៀបចំការបោះឆ្នោតឃើញថាមានការវិវឌ្ឍន៏កាន់តែល្អប្រសើរ មានការរីចចំរើនជាលំដាប់អំពីសមត្ថភាពការយល់ដឹងការដឹកនាំគ្រប់គ្រងការចាត់ចែងអនុវត្តនិងកិច្ចសហការជាពិសេសការចូលរួមទទួលខុសត្រូវពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ លោកស្រីក៏បានរំលើកឡើងវិញថា អ្វីដែលទទួលបានការជោគជ័យនៅក្នុងការរៀបចំការបោះឆ្នោតមិនមែនតែលេខាធិការដ្ឋានរៀបចំការបោះឆ្នោតនិងគណៈកម្មាធិការធ្វើតែម្នាក់ឯងទេ ហើយលោកស្រីក៏បានធ្វើការសសើរដល់ភាគីដែលពាក់ព័ន្ធ នរគលបាន ខាងរាជអាវុធហត្ថ ខាងអាជ្ញាធរដែនដី ខាងគណបក្ស ជាពិសេសយើងតែងតែបានរួមគ្នាហើយជជែកគ្នាចូលរួមយ៉ាងសកម្មក្នុងការធ្វើយ៉ាងណាអោយការបោះឆ្នោតទទួលបានជោគជ័យ ហើយលទ្ធផលដ៏ល្អនេះក៏មិនអាចផ្តាច់បានពីកិច្ចសហការណ៏ តាមដានកែលំអរជាប់ជាប្រចាំរបស់អង្គការសង្គមស៊ីវិលនានា។

បើយើងពិនិត្យមើលទៅក្រោយ ហើយប្រៀបធៀបរវាងការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០២ និងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០០៣ យើងអាចទទួលស្គាល់បានថា យើងមានការអភិវឌ្ឍន៏ជាមូលដ្ឋាន។ កត្តារីកចំរើនគួរអោយកត់សំគាល់គឺសន្លឹកឆ្នោតមិនបានការថយចុះ ពីការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ មកការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ គណបក្សនយោបាយមានភាពចាស់ទុំប្រកាន់ភ្ជាប់នូវស្មារតីប្រជាធិតេយ្យក្នុងយុទ្ធនាការណ៏ឃោសនាបោះឆ្នោត ហើយភាពយល់ច្រឡំមិនទុកចិត្តគ្នា និងភាពរអើងផ្សេង១ត្រូវបានកាត់បន្ថយ និងបរិយាកាសសន្តិសុខល្អជាទូទៅ ដោយសារគណៈកម្មាធិការជាតិបានរៀបចំអោយមានកិច្ចប្រជុំរវាងគណបក្សទាំងអស់ និងសង្គមស៊ីវិលទាំងឡាយព្រមទាំងភាគីពាក់ព័ន្ធទាំងអស់រាល់សប្តាហ៏។

ប្រជាពលរដ្ឋចុះឈ្មោះបោះឆ្នោតក្នុងការជ្រើសរើសតំណាងរាស្ត្រអាណត្តិទី២ នៅឆ្នាំ១៩៩៨មាន១៥៧៧២នាក់ ប៉ុន្តែអ្នកមកបោះបាន១២៤៤៣នាក់ដែលស្មើនិង៧៦.៨ភាគរយ។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០២ អ្នកចុះឈ្មោះមានតែ១៤៤៧២នាក់ អ្នកមកបោះឆ្នោតមានចំនួន១២១២៩នាក់ស្មើនិង៨១ភាគរយ។ ក៏ប៉ុន្តែនៅពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅ

អាណត្តិទី៣ឆ្នាំ២០០៣ យើងចុះឈ្មោះបានដល់ទៅ២២៩៣៤នាក់ ប៉ុន្តែអ្នកមកបោះឆ្នោតបានតែ១៥៩២៤នាក់វិញ គឺវាស្មើតែ៦៩ ភាគរយដែរ។ ទាំងអស់គ្នាឆ្ងល់ហើយថា ហេតុម៉េចបានចុះឈ្មោះបានច្រើន ហើយ អ្នកមកបោះបានតិច ? លោកស្រីក៏បានបញ្ជាក់ថា ហេតុផលនៃចំនួនអ្នកបោះឆ្នោតបានតិចនេះគឺថា ទី១ នៅឆ្នាំ២០០១នេះយើងបាន ធ្វើប្រតិភូកម្មអំណាចអោយក្រុមប្រឹក្សាគាត់ជាអ្នកធ្វើការចុះឈ្មោះ ពីមុនការងារនេះខាងគណៈកម្មធិការជាអ្នកធ្វើ ប៉ុន្តែនៅឆ្នាំ២០០១ ក្រសួងមហាផ្ទៃនិង គជប បានធ្វើប្រតិភូកម្មអំណាចអោយក្រុមប្រឹក្សាឃុំសង្កាត់គាត់ជាអ្នកធ្វើការចុះឈ្មោះ អញ្ចឹងក្នុងដំណាក់កាល ចុះឈ្មោះនេះដោយសារគាត់ជាអ្នកធ្វើការងារថ្មី អញ្ចឹងបញ្ហាខ្វះខាតនៅមានចន្លោះតិចតួច ដូចជាជួនកាលប្រជាពលរដ្ឋនៅពេលដែលគាត់ចុះឈ្មោះហ្នឹង ព្រំដែនថៃត្រូវបិទ អញ្ចឹងយើងចុះបានច្រើន ប៉ុន្តែដល់ពេលបោះគាត់ចេញទៅរកស៊ីនៅដីថៃវិញអស់ ដោយសារទីក្រុងប៉ៃលិនរបស់យើងនៅជាប់និងព្រំដែនដល់ពេលអញ្ចឹងទៅយើងអត់មានមនុស្សមកបោះ។ ទី២ ទៀតចំពោះបញ្ហាអ្នកដែលរកស៊ី នៅព្រំដែនដែលមានហៅថា កន្លែងមួយចំនួនដែលអ្នកធ្វើការ ហើយពួកនេះគេសិតតែចល័តដែរ យើងចុះបាន២០០-៣០០នាក់អញ្ចឹង ទៅអ្នកធ្វើការនៅកន្លែងហ្នឹង ប៉ុន្តែដល់ពេលបោះ ពួកហ្នឹងត្រូវវិលកន្លែងធ្វើការត្រូវបិទអីអញ្ចឹង កន្លែងក៏វារំសាយទៅ នេះជាមូលហេតុមួយដែលធ្វើអោយអ្នកមកបោះមិនបានច្រើន ។ ប៉ុន្តែបើយើងប្រៀបធៀបមើលជាតួលេខអ្នកបោះឆ្នោតនៅឆ្នាំ២០០២មាន ១២១២៩នាក់មកពេលបោះឆ្នោត២០០៣ យើងបាន១៥៩២៤នាក់ បើយើងមើលជាតួលេខឃើញថាជាតួលេខមួយដែលវាសមស្របវិញ ពិព្រោះការចុះគាត់ចុះបានតែមកបោះកាត់មកបោះមិនបាន អញ្ចឹងពេលដែលចុះនោះគាត់អត់បានគិតថា តើអ្នកហ្នឹងនៅជាប់ដល់ពេលបោះទេ ឬមួយយ៉ាងម៉េចទេ ពិព្រោះជានីតិវិធីយើងអោយតែគេមកសុំចុះ យើងចុះអោយទាំងអស់ អញ្ចឹងបានន័យថាអ្នកដែល មកចុះឈ្មោះនៅទីនេះមិនប្រាកដថាបានមកបោះទាំងអស់គ្នាទេ ជួនកាលគាត់ចេញទៅរកស៊ីនៅប្រទេសថៃបាត់ទៅ គាត់ក៏អត់បានមកបោះដែរ ។

ដើម្បីបំពេញនូវចំនុចខ្វះចន្លោះដូចជា ការចុះឈ្មោះមានរយៈពេលខ្លី ប្រជាពលរដ្ឋមិនមានឱកាសដើម្បីរកឯកសារមកចុះឈ្មោះបាន ហើយនៅក្នុងឆ្នាំ២០០៥នេះ គជប ក៏បានណែនាំនីតិវិធីថ្មីដូច លោក ឱក សេរីសោភក្តិ៍ បានមានយោលបល់ហើយថា ការចុះឈ្មោះត្រៀម។ ការចុះឈ្មោះត្រៀមនេះយើងធ្វើពីខែមករាដល់ខែកញ្ញា ហើយព្រមជាមួយគ្នានេះ គជប ក៏បានធ្វើវិសោធនកម្មលើបញ្ជីឈ្មោះដោយដាក់ឈ្មោះតាមអក្ខៈក្រមវិញ បានន័យថាយើងរៀបឈ្មោះតាម ក ខ គ ឃ ង វិញ អញ្ចឹងទៅធ្វើអោយប្រជាពលរដ្ឋគាត់ងាយស្រួលរកមើលឈ្មោះ ព្រោះកន្លងមកយើងយកលេខរៀងប័ណ្ណជាធំ ដោយយកលេខរៀងប័ណ្ណទៅ ដូចថាឈ្មោះ ក អញ្ចឹងជួនកាលវាទៅនៅក្រោមគេ ឥឡូវនេះឆ្នាំ២០០៥យើងបានបង្វិលបញ្ជីហើយគឺថា ក មកមុនទៅ ដូចឈ្មោះខ្ញុំអក្សរ អ នៅក្រោមគេ ដល់ពេលយើងរកទៅវាងាយស្រួលក្នុងការរកឃើញឆាប់រហ័សដែរ។

ហើយយើងបានថែមបញ្ហាមួយទៀតគឺ រយៈពេលត្រៀមនេះក្រុមប្រឹក្សាឃុំសង្កាត់ គាត់សហការណ៍ជាមួយខាងលេខាធិការដ្ឋានចុះស្រង់ស្ថិតិប្រជាពលរដ្ឋ ពិនិត្យមើលអ្នកផ្លាស់ចេញ អ្នកផ្លាស់ចូល ស្រង់ឈ្មោះអ្នកដែលមិនទាន់បានចុះឈ្មោះអី តែជារយៈពេលត្រៀម។ ហើយម្សិលមិញខ្ញុំបានប្រជុំជាមួយគណបក្សនិងអាជ្ញាធរមួយចំនួន ដើម្បីត្រួតពិនិត្យការងារមួយចំនួន ហើយក៏មានសំណូមពរមួយដែលខ្ញុំសូមលើកតែម្តងទៅគឺថា មានគណបក្សមួយចំនួនស្នើថា បើយើងមិនបាច់ត្រៀមយើងចុះតែម្តងទៅបានឬអត់ ? នេះជាសំណូមពរដែលគណបក្សបានផ្តាំផ្ញើនេះខ្ញុំគ្រាន់តែផ្តល់ជូនទៅវេទិការដើម្បីពិភាក្សាគ្នានៅក្នុងថ្ងៃនេះតែប៉ុណ្ណោះ។ ហើយឥឡូវនេះយើងមានថែមទៀត ពីលើការត្រៀមនោះគឺជូនដំណឹងមួយទៀត។ យើងជូនដំណឹងពេលបោះឆ្នោតនេះគឺថា ធ្វើម៉េចអោយប្រជាពលរដ្ឋគាត់ត្រៀមថា តើឈ្មោះគាត់ខុសឬត្រូវ អាយុគាត់ខុសឬត្រូវ ព្រោះដើម្បីអោយដំណើរការទៅថ្ងៃមុខដែលយើងយកអត្តសញ្ញាណប័ណ្ណមកបោះបាននោះគឺថាបញ្ជីឈ្មោះវាត្រូវការកែចុះកែឡើងច្រើនណាស់។

ហើយការចែកប័ណ្ណព័តិមានដែលយើងបានធ្វើ២សប្តាហ៏កន្លងមកនេះ ខ្ញុំឃើញថាមានបញ្ហាដែលយើងជួបប្រទះជាច្រើនមកហើយ។ ទី១ ការចែកប័ណ្ណនេះយើងធ្វើនៅមានចង្វាក់យឺត ដោយសារប្រជាពលរដ្ឋពេលថ្ងៃគាត់ទៅចំការបាត់ទៅយើងរកគាត់អត់ជួប ហើយការប្រមូលផ្តុំមានការពិបាកដោយសាររដូវនេះជារដូវធ្វើស្រែចំការ ហើយម្យ៉ាងទៀតឃើញថា ឈ្មោះមានការខុសច្រើនដែលធ្វើអោយមានការពិបាកនៅក្នុងការផ្តល់ប័ណ្ណព័តិមាននេះ តែយើងក៏ខំប្រឹងធ្វើការដោះស្រាយថា ធ្វើម៉េចយើងផ្តល់ប័ណ្ណនេះទៅដល់គាត់សិន ការកែលំអរយ៉ាងណាយើងនឹងធ្វើតាមក្រោយនៅខែតុលា។ ហើយតាមរយៈប័ណ្ណព័តិមានអ្នកបោះឆ្នោតនេះយើងអាចប្រមូលបានព័តិមានជាក់លាក់ បើអ្នកណារកមិនឃើញគឺរកមិនឃើញតែម្តង គឺគាត់គ្មានទីលំនៅគាត់ផ្លាស់ចេញទៅបាត់ គឺដើរកគាត់អត់ឃើញតែម្តង អញ្ចឹងវាជាក់លាក់ជាងកាលអោយគាត់មកមើល ពិព្រោះបញ្ជីឈ្មោះយើងដែលប៉ោងបន្តបន្ទាប់មកដោយសារយើងអត់ហ៊ានលុបគេ កាលពិតអ្នកនោះមានឈ្មោះតាំងពី២០០៣ ក៏ប៉ុន្តែមកដល់២០០៦នេះគាត់លក់ដីទៅនៅស្រុកណាបាត់ទៅហើយ តែនីតិវិធីច្បាប់យើងលុបមិនបានទេ លុះត្រាតែយើងមានឯកសារផស្តុតាងច្បាស់លាស់ អញ្ចឹងហើយការចែកប័ណ្ណព័តិមាននេះវាក៏ជួយមួយក៏រិតធ្វើអោយយើងរកឃើញថា តើអ្នកដែលមានទីលំនៅអចិន្ត្រៃយ៏ពិតប្រាកដប៉ុន្មាន អ្នកផ្លាស់ចេញទៅហើយនោះប៉ុន្មានជាក់លាក់ជាងមុនដែរ។

ជារួមក្នុងការបោះឆ្នោតនិមួយៗយើងមាន៤ដំណាក់កាលធំៗ គឺការចុះឈ្មោះ យុទ្ធនាការឃោសនា ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។ ហើយខ្ញុំយល់ថា ការរៀបចំដំណើរការនៃរាល់ដំណាក់កាលនិមួយៗ មានការងារច្រើនណាស់ដែលគណៈកម្មធិការត្រូវធ្វើក្នុងរយៈពេលមួយក៏ខ្លី ហើយថវិការមានកំណត់។ ដោយសារពេលវេលាខ្លី លេខាធិការយើងមានការពិបាកក្នុងការធ្វើការបណ្តុះបណ្តាល ការអប់រំផ្សព្វផ្សាយ ដល់មន្ត្រីបោះឆ្នោតក៏ដូចជាសាធារណៈជនទូទៅ គណបក្សនានា ឬអង្គការសង្គមស៊ីវិលនានាអោយយល់ជាក់លាក់ពីនីតិវិធីដែលត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតនីមួយៗដែរ។ ព្រោះបើមន្ត្រីការិយាល័យយើងបង្រៀនបានតែ៣ថ្ងៃទេ ហើយចេញធ្វើការតែម្តង ហើយមន្ត្រីឃុំសង្កាត់ក៏ដូចគ្នា អញ្ចឹងទៅវាមានការលំបាកដែរ។ ហើយជាច្បាប់ទាំងគណៈកម្មាធិការខេត្ត ទាំងគណៈកម្មាធិការឃុំ ទាំងមន្ត្រីការិយាល័យ ត្រូវតែរើសរាល់លើកនៅពេលធ្វើការបោះឆ្នោត ដោយសារតែរយៈពេលខ្លីយើងមិនអាចធ្វើការបណ្តុះបណ្តាលបានច្រើន ដូច្នេះហើយការអនុវត្តជួនកាលវាមានការភាន់ភាំងខ្លះដែរ ជាពិសេសមន្ត្រីការិយាល័យដែលយើងជួបការលំបាកច្រើន ពិព្រោះអីការិយាល័យយើង៤២កាលពេលបោះឆ្នោតតំណាងរាស្ត្រ ឥឡូវនេះឆ្នាំ២០០៧ប្រហែលជាឡើងដល់៥៣ ហើយក្នុងមួយការិយាល័យយើងនឹងបន្ថែមមនុស្សម្នាក់ទៀតសំរាប់អ្នកជួយរកមើលឈ្មោះ អញ្ចឹងយើងត្រូវការមនុស្សយ៉ាងតិច៣០០នាក់ជាងដើម្បីបំពេញការងារនេះ ហើយក្រុងប៉ៃលិនយើងមានវិបត្តិដែរខាងធនធានមនុស្ស ហើយបើសិនជាក្រុមប្រឹក្សាឃុំសង្កាត់មានច្បាប់ចែងថាត្រូវតែរើសនៅក្នុងភូមិសង្កាត់ទៀតនោះយើងនឹងជួបការលំបាកកាន់តែច្រើនដែរ។ តែខ្ញុំនឹងខិតខំអោយអស់ពីលទ្ធភាពស្រាវជ្រាវរកមន្ត្រីដើម្បីទៅបំពេញការងារដែរ ពិព្រោះអីឆ្នាំក្រោយនេះយើងត្រូវការមនុស្ស៣០០នាក់ជាង ដើម្បីទៅបំពេញការងារនៅតាមការិយាល័យបោះឆ្នោតនេះ ។ យើងក៏បានជួបប្រជុំគ្នាជាបន្តបន្ទាប់ដែរ ហើយខ្ញុំក៏ព្យាយាមអនុវត្តនូវគោលការណ៏របស់ គជប គឺថាផ្សព្វផ្សាយ ដោយឥឡូវនេះយើងអត់មានលាក់លៀមគ្នាទេ ដូចជាការចែកប័ណ្ណព័តិមាននេះចែករប្រៀបម៉េចធ្វើរប្រៀបម៉េច គឺយើងអញ្ជើញគណបក្សនិងសង្គមស៊ីវិលមករៀនទាំងអស់ សូម្បីតែបោះឆ្នោតព្រឹទ្ធសភា តើនីតិវិធីយ៉ាងម៉េច ?ការរាប់យើងអញ្ជើញគណបក្សមកចូលរួមទាំងអស់ដើម្បីអោយគាត់បានដឹងឮគាត់យល់ទៅ គាត់ជួយពិនិត្យ ជួយធ្វើយើងបានល្អ។

កន្លងមកយើងបានរកឃើញចំនុច បច្ចេកទេសខ្វះខាតមួយចំនួនគឺថា ទីតាំងមួយចំនួនឋិតនៅក្នុងផ្ទះប្រជាពលរដ្ឋនៅឡើយ ហើយឆ្នាំនេះក៏យើងព្យាយាមធ្វើការផ្លាស់ប្តូរទៀត ប៉ុន្តែការផ្លាស់ប្តូរនេះ អស្រ័យដោយគណបក្សទាំងអស់យល់ ហើយក្រុមប្រឹក្សាឃុំសង្កាត់ ហើយប្រធានភូមិយល់ ហើយធ្វើយ៉ាងណាផ្សព្វផ្សាយអោយទាន់ពេលវេលា ដើម្បីជាសវាងទៅបោះខុសការិយាល័យដូចឆ្នាំ

២០០៣ទៀត។ ប៉ុន្តែបើដំណោះស្រាយមិនចេញទេ យើងអាចមានដំណោះស្រាយល្អមួយគឺ ការបោះតង់ ហើយខ្ញុំក៏ជឿថានេះនេះក៏យើងឯកភាពគ្នាដែរ ថាបើសិនជាយើងជួរមិនបានទេ យើងយកផ្ទះហ្នឹងដដែរ តែយើងអត់បោះនៅក្នុងផ្ទះទេ យើងបោះតង់នៅមុខផ្ទះចូលបោះដូចយើងធ្វើនៅផ្ទះលោក រុង រឿង អញ្ចឹង។

ទី២ ទៀតយើងឃើញថា ការបិទបញ្ជីឈ្មោះ នៅចំមុខទ្វាចូលនោះវាធ្វើអោយមនុស្សកកកុញគ្នា ពេលបោះព្រឹកឡើងមនុស្សសំរុកហើយទាំងអ្នករកស៊ី និងអ្នកប្រញាប់ទៅចំការគឺគាត់មកហើយពេលព្រលឹមហ្នឹង ហើយពេលហ្នឹងនីតិវិធីយើងគឺយកឈ្មោះទៅបិទអោយគាត់មើលមុនសិន មុននឹងគាត់ចូល ហើយនៅពេលបិទយើងមិនបានប្រយ័ត្នប្រយែងយើងបិទនៅមាត់ទ្វាចូលតែម្តងធ្វើអោយមានការរាំងស្ទះ អញ្ចឹងលើកនេះដំណោះស្រាយដែលយើងរកឃើញ គឺយើងអាចបិទនៅលើជញ្ជាំងនៅឆ្ងាយពីទ្វា ដើម្បីគាត់ទៅរកមើលនៅខាងនោះហើយបានគាត់ដើចូលមកបោះក្រោយវាធ្វើអោយទូលាយបន្តិចដែរ។

ហើយឆ្នាំនេះយើងនឹងមានមន្ត្រីម្នាក់បន្ថែមទៀត សំរាប់ជួយរកមើលឈ្មោះ ព្រោះឯកឧត្តមអគ្គលេខាធិការ គជប គាត់បានប្រកាសហើយ យើងនឹងបន្ថែមមន្ត្រីការិយាល័យម្នាក់ទៀត ដើម្បីជួយរកមើលឈ្មោះប្រជាពលរដ្ឋខាងក្រៅ។ ហើយទន្ទឹមនិងនេះយើងក៏រកឃើញដែលថា ការប្រជុំប្រចាំសប្តាហ៍រវាងគណបក្ស និងភាគីពាក់ព័ន្ធ ជាពិសេសខាងផ្នែកសន្តិសុខសណ្តាប់ធ្នាប់នេះ ឃើញថាជាការលើកទឹកចិត្តមួយល្អណាស់ ហើយខ្ញុំនឹងខិតខំធ្វើយ៉ាងណាអោយវប្បធម៌នៃការពិភាក្សាគ្នា ដើម្បីដោះស្រាយទំនាស់ដោយសន្តិវិធីនេះអោយវាបានល្អនៅក្រុងប៉ៃលិនយើងនេះ។

សរុបមកយើងបានរកឃើញនូវចំនុចខ្លះ ហើយខ្ញុំជឿជាក់ថាខ្ញុំនិយាយមិនអស់ទេ មានតែវាគ្មិនដែលចូលរួមនៅក្នុងអង្គប្រជុំថ្ងៃនេះទេដែលជួយបញ្ចេញយោបល់បន្ថែមទៀត ដើម្បីចូលរួមចំនែកនៅក្នុងការអនុវត្តលទ្ធិប្រជាធិតេយ្យ ស្មារតីក្នុងការចូលរួមកែលំអរអ្វីដែលបានសម្រេចលទ្ធផលធ្វើរួចពីអតីតកាលជាការល្អប្រសើរណាស់ ពិព្រោះយើងគិតថា បើសិនយើងគិតថាខ្លួនយើងធ្វើល្អហើយមិនបាច់កែទេ ខ្ញុំឃើញថាវាហាក់ដូចជាគ្មានការរីកចំរើនដែរ ពិព្រោះពេលដែលយើងប្រជុំម្តងៗ ខ្ញុំតែតែឃើញមានគំនិតប្លែកៗដូចជាគណបក្សលោកបានលើកថាចុះបើត្រៀមហ្នឹងចុះតែម្តងទៅវាមិនស្រួលជាង នេះវាគ្រាន់តែជាគំនិតមួយទេ ហើយយើងមានគំនិតផ្សេងៗទៀតដែល យើងអាចយកមកជជែកគ្នា ប៉ុន្តែការធ្វើបានឬមិនបាន ក៏នៅលើការជជែកគ្នានៅលើការយល់គ្នាថែមទៀតមិនមែនថាខ្ញុំលើកហើយត្រូវតែធ្វើអោយបានទេ ព្រោះអីច្បាប់វាចែងមកអញ្ចេះ នីតិវិធីវាចែងមកអញ្ចេះ បើលោកចង់កែវាត្រូវកែច្បាប់ អញ្ចឹងបានថាអ្វីដែលយើងជជែកថ្ងៃនេះ បញ្ហាខ្លះក៏យើងខំប្រឹងប្រែងដែរ ធ្វើម៉េចយកច្បាប់និងនីតិវិធីមកជជែកកែលំអរនៅក្នុងក្របខ័ណ្ឌនេះវាមានលទ្ធផលល្អ ប៉ុន្តែអ្វីដែលមានការសំណូមពរទៅដល់ការកែប្រែច្បាប់ខ្ញុំសូមប្រគល់ជូនលោកឱក សេរីសោភក្តិ ហើយសំរាប់យកទៅពិភាក្សានៅថ្នាក់ជាតិក្នុងបញ្ហានេះ។

ខ្ញុំសង្ឃឹមថាថ្ងៃនេះ យើងនឹងរកអនុសាសន៍សំណូមពរផ្សេងៗទៀត ដើម្បីនឹងរៀបចំការបោះឆ្នោតនេះអោយកាន់តែល្អប្រសើរហើយលទ្ធិប្រជាធិតេយ្យជារបបមួយដែលសកលលោកប្រាថ្នាចង់បាន តែការអនុវត្តនិងការយល់ដឹងខ្ញុំឃើញថាវាមានការខុសប្លែកគ្នាពីប្រទេសមួយៗវាមិនអាចដូចគ្នាទាំងស្រុងទេ ពិព្រោះបរិយាកាសសង្គម ក៏រិតធនធានមនុស្ស កំរិតយល់ដឹង ជាពិសេសក៏រិតជីវភាពរបស់ប្រជាពលរដ្ឋនេះ ប្រព័ន្ធផ្សព្វផ្សាយ ប្រព័ន្ធថវិការ ប្រព័ន្ធបច្ចេកវិជ្ជាទាំងអស់ដែលយកមកប្រើប្រាស់វាសិតតែជាកត្តាកំណត់មកលើកិច្ចដំណើរការនេះទាំងអស់។

**លោក ឱក សេរី សោភក្តិ** បានថ្លែងអំណរគុណដល់លោកស្រី ម៉ៃ ណាត់ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតក្រុងប៉ៃលិននេះ។ យើងនឹងធ្វើការប្រជុំនេះនៅ ក្រុងប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តពោធិសាត់ និងខេត្តកំពង់ឆ្នាំងគឺមានប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតជាស្ត្រី៣នាក់ ហើយពេលដែលយើងទៅប្រជុំនៅគ្រប់ខេត្តនោះ យើងឃើញថា

ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតនេះមានសមត្ថភាពណាស់ ហើយយើងក៏មានការកោតសសើរណាស់ចំពោះ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតជាស្ត្រីពនាក់នៅ ក្រុងប៉ៃលិន ខេត្តបន្ទាយមាជ័យ និងខេត្តកំពង់ឆ្នាំងដែលមានប្រធានលេខាធិការដ្ឋានជាស្ត្រីនេះ ។ បងស្រីបានមានប្រសាសន៍ថាយើងខ្វះធនធាន តែយើងមើលទៅនៅប្រទេសកម្ពុជាយើងឃើញថាធនធានស្ត្រីដែលមានសមត្ថភាពប្រហែលជាកាន់តែកើនឡើង កាន់តែច្រើនឡើងហើយ ។

**លោក កែវ សុមេទ្ធ ប្រធានអង្គការសហគមអភិវឌ្ឍន៍តាមព្រំដែនកម្ពុជាប្រចាំទីក្រុងប៉ៃលិន** (CBCDO) លោកបានមានប្រសាសន៍ថា ពីមុនលោកជាអតីតសមាហរណកម្ម ហើយរស់នៅតាមព្រំដែនចាប់ពីកោះកុងរហូតដល់ម៉ាឡៃ ហើយនៅឆ្នាំ១៩៩៦ លោកបានពិនិត្យមើលឃើញពីគោលនយោបាយលទ្ធប្រជាធិតេយ្យ ពេលនោះលោកជាអ្នកបំរើក្នុងសង្គ្រាមជាង២០ឆ្នាំដែល ឃើញមានតែការប្រយុទ្ធ ហើយពេលនោះខ្ញុំឃើញមាន NGOs ហើយដើម្បីបង្កើតនូវលទ្ធិប្រជាធិតេយ្យគឺមានសង្គមស៊ីវិល ហើយខ្ញុំក៏ឈប់ធ្វើទាហាន ហើយមកធ្វើការនៅក្នុង NGOs ហើយអង្គការខ្ញុំបង្កើតឡើងនូវថ្ងៃទី៩ខែមករាឆ្នាំ២000 ហើយបានច្បាប់ពីក្រសួងមហាផ្ទៃនៅថ្ងៃទី២៧ខែមីនាឆ្នាំ២០០១ ហើយខ្ញុំធ្វើសកម្មភាពនៅទីក្រុងប៉ៃលិនតាំងពីឆ្នាំ២000មក។ ហើយខ្ញុំក៏បានដឹងដែលថា ឆ្នាំ១៩៩៣ទីក្រុងប៉ៃលិនមិនបានបោះឆ្នោតទេ យើងទើបតែបោះឆ្នាំ១៩៩៨។ ហើយកាលនោះខ្ញុំធ្វើការនៅអង្គការមួយចំនួននៅខេត្តបាត់ដំបង ហើយខ្ញុំបានសហការណ៏ជាមួយ ខមហ្វ្រែល ដែលកាលនោះ ខមហ្វ្រែល គាត់ធ្វើការរត់ចុះរត់ឡើង ហើយកាលនោះខ្ញុំមានឥទ្ធិពលនៅព្រំដែនខ្ញុំជួយចែកឯកសារគាត់បានទាំងអស់នេះខ្ញុំនិយាយត្រួស១ពី១៩៩៨។ អង្គការខ្ញុំមានកម្មវិធី៤គឺ អភិវឌ្ឍន៍សហគមន៍ បរិស្ថាន សិទ្ធមនុស្ស និងសុខភាព។

ហើយបញ្ហាបោះឆ្នោតខ្ញុំបានចូលប្រឡូកនៅក្រុងប៉ៃលិន នៅក្នុងការឃោសនា ហើយបញ្ហាគណបក្សនិមួយៗមិនទាន់បានជជែកគ្នាទេ ឧទាហរណ៏ថា នៅជួរជាមួយគ្នាគ្រាន់តែគាត់ធ្វើមេឃុំមុន ឬក៏ធ្វើអីមុនហ្នឹង ពេលដែលគាត់ទៅចូលបក្សមួយទៀតស្រាប់តែគាត់ថា អាណ្ហឹងខ្ទមតូចម្លេះ ហើយចង់បានកៅអីឯង គាត់អត់បានយល់ថាលទ្ធិប្រជាធិតេយ្យនេះត្រូវមានការអង្គុយទល់មុខគ្នាទេ ហើយខ្ញុំក៏បានជួយដែរគឺថា យើងត្រូវតែអង្គុយជាមួយគ្នាអញ្ចឹង ព្រោះយើងអត់អាចចែកផ្លូវគ្នាដើរបានទេ នេះមួយគ្រាន់តែបញ្ហាគណបក្ស ក គណបក្ស ខ ចូលមកប្រកួតប្រជែងគឺគាត់អត់បានយល់គ្នា។

បញ្ហា១ទៀត គឺការយល់ដឹងពីច្បាប់នៅមានកំរិត ព្រោះការអប់រំនៅប៉ៃលិនមានតិចតួច ច្បាប់រៀនមិនបានអស់ទេ។ ជូនកាលរៀនតែអ្នកធំ អ្នកតូចមិនបានរៀន អញ្ចឹងអ្នកដែលទទួលឥទ្ធិពលពីបក្សចេះតែដើរនិយាយហើយ ។

ហើយទី៣ បញ្ហាទំនាស់ គឺក្តាប់មិនសូវបានទេ គាត់ច្រើនតែយកវិធានការណ៏តែម្តង។ អញ្ចឹងមុននឹងដោះស្រាយទំនាស់ទាល់តែយើងក្តោបក្តាប់ទំនាស់បានគ្រប់ពេលវេលា ថាទំនាស់នោះកើតពីណា កើតពីបុគ្គល ឬកើតពីគណបក្ស នេះគឺគាត់ក្តាប់មិនបានទេ ដូច្នេះទាល់តែយើងក្តាប់ទំនាស់បាន បានអាចធ្វើការដោះស្រាយបាន បើសិនចាត់វិធានការតែម្តងគឺមានបញ្ហា។

បញ្ហាឃោសនា គឺថាគណបក្សខ្លះមានអំណាច គាត់ថាបើឯងចង់ធ្វើមេឃុំ កុំដើរផ្លូវអញ អណ្តូងទឹកអញ ហើយម៉េចក៏មិនចែកអំណោយទៅផងទៅ នេះវាប៉ះពាល់ខ្លាំងណាស់ ហើយនេះខ្ញុំលើកជាក់ស្តែង ព្រោះបានតាមដានដែរ។ គាត់អត់គិតថាការដែលគាត់និយាយបែបនេះគឺគាត់ជាអ្នកដឹកនាំរដ្ឋាភិបាល អញ្ចឹងបញ្ហានេះយើងត្រូវតែគិតដែរថា អ្វីដែលធ្វើឡើងនេះគឺរដ្ឋាភិបាល រដ្ឋាភិបាលមុននឹងគាត់មានមុខនិយាយគឺគាត់មាន៩០កៅអី គាត់មិនអាចមកនិយាយ ធ្វើអណ្តូងទឹក ធ្វើផ្លូវថ្នល់ សាលារៀន តែម្នាក់ឯងបានទេ គឺមាន១២៣កៅអីនៅក្នុងរដ្ឋសភា។

បញ្ហាការចុះឈ្មោះ ខ្ញុំឃើញថាពេលចុះឈ្មោះបោះឆ្នោត គឺមានការឃោសនាផ្សព្វផ្សាយជូនកាលឆ្ងាយពេកគាត់ទៅចុះឈ្មោះអត់បាន ជូនកាលគាត់ដូរកន្លែង។ ប៉ុន្តែការចុះឈ្មោះបោះឆ្នោត អត់បានផ្សព្វផ្សាយអោយទូលំទូលាយជូនកាលថាគាត់រវល់។

ហើយ១ទៀតការបោះឆ្នោត គាត់ទៅរកឈ្មោះមិនឃើញ ការដូរឈ្មោះចុះឡើង ព្រោះមួយការិយាល័យយើងមានតែ៧០០ នាក់តែកាលណាលើសទៅដូរអត់បាន។

ខ្ញុំសូមសំណូមពរទៅខាងលោកស្រីប្រធានគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្តថា នៅពេលដែលមានការចុះឈ្មោះសូមអោយបានជិត១ និងសូមអោយលោកស្រីទំនាក់ទំនងជាមួយអង្គការ NGOs យើងខ្លះផងដើម្បីអោយយើងបានចូលរួមនៅក្នុងរឿងនេះ។

**លោក ប៉ុល ជួន ចៅសង្កាត់រងទី១ ស្ទឹងកាច់** ខ្ញុំមានសំណូមពរថា ទី១ គឺសូមជួយធ្វើយ៉ាងណាកុំអោយមានការរើសអើងគណបក្សនិមួយៗ ព្រោះថាបើមានការរើសគឺមានបញ្ហាខ្លះណាស់ ធ្វើអោយក្នុងសង្គមមានការពិបាក ហើយផលប្រយោជន៍អ្វីដែលកើតឡើងពីប្រជាជនត្រូវការចង់ធ្វើអ្វីមួយ រើសអញ្ចេះ រើសអញ្ចុះទាំងលោកមេភូមិ ទាំងលោកមេឃុំ នេះជាបញ្ហាមួយសំខាន់បំផុត។

**លោក ប៊ុន គីមសេង ចៅសង្កាត់រងទី១ បយ៉ាខា** យោលបល់របស់ខ្ញុំគឺពាក់ព័ន្ធនឹងកិច្ចការងារបោះឆ្នោតនៅពេលខាងមុខក៏ដូចជាត្រៀមសំរាប់ធ្វើបញ្ជីបោះឆ្នោត។ កន្លងមកខ្ញុំពិនិត្យឃើញពាក់ព័ន្ធនឹងការបោះឆ្នោតទាំង៣លើក យុទ្ធនាការនៃការឃោសនាបោះឆ្នោតរវាងគណបក្សនយោបាយនិមួយៗតែងតែមានបញ្ហានឹងគ្នា អំពីការឃោសនាជេរគ្នា បញ្ហានេះខ្ញុំឃើញថា ខ្មែរយើងបាត់បង់វប្បធម៌មួយហើយ ជាសំណូមពររបស់ខ្ញុំធ្វើម៉េចគណបក្សនយោបាយនិមួយៗ ការឃោសនាបោះឆ្នោតសូមថាមិនបាច់ជេរគ្នាទេ យើងនិយាយតែពីគោលនយោបាយរបស់គណបក្សនយោបាយនិមួយៗទៅបានហើយ។ ហើយការប្រើប្រាស់ឃោសនាស័ព្ទនេះ ខ្ញុំក៏ឃើញថាបាត់បង់សីលធម៌មួយដែរ ជួនកាលនិយាយស្តាប់គ្នាមិនបានទេ ប្រជាពលរដ្ឋដល់គាត់ធុញពេកគាត់ទៅចំការបាត់គាត់អត់ស្តាប់ទេ ព្រោះមិនដឹងថា តើគោលនយោបាយរបស់គណបក្សណាល្អជាងនរណាទេ បើដាក់ឃោសនាស័ព្ទទល់គ្នាអញ្ចឹង វាទៅជាស៊ីទៅវិញទៅធ្វើអោយប្រជាពលរដ្ឋគាត់ធុញទ្រាន់។

បញ្ហាទី២ ពាក់ព័ន្ធនឹងការងារចុះឈ្មោះ។ កន្លងមកចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីអ្នកបោះឆ្នោតមានចំនួនច្រើន ក៏ប៉ុន្តែលទ្ធផលនៃការបោះឆ្នោតវាអត់តុល្យភាពគ្នានិងការចុះឈ្មោះទេ ដោយមានបញ្ហាជាច្រើន។ ពិសេសខ្ញុំនិយាយតែពីសង្កាត់ខ្ញុំទេ កន្លងមកយើងមានគោលការណ៍មួយ និយាយពីច្បាប់នៃការរៀបចំការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគឺថា អោយតែខ្មែរគឺគាត់មានសិទ្ធបោះឆ្នោត កន្លងមកអាជ្ញាធរខ្ញុំមិនចង់អោយមានការចុះឈ្មោះអញ្ចឹងទេ ចង់ថាអោយអ្នកដែលមានអាសយដ្ឋានមានមូលដ្ឋានត្រឹមត្រូវបានយើងអោយគាត់ចុះឈ្មោះ ប៉ុន្តែក្រោយមក បានន័យថា មានបងប្អូនមករកស៊ីអញ្ចឹងគាត់អត់មានអត្តសញ្ញាណអីទេ អញ្ចឹងអាជ្ញាធរគាត់មិនចុះឈ្មោះអោយទេ អញ្ចឹងគណបក្សនយោបាយខ្លះជំទាស់ ព្រោះគាត់ជាខ្មែរ ហើយជនដែលមកចុះឈ្មោះនោះមិនមានឯកសារអីទាំងអស់មិនដឹងជាគាត់ជាស៊ីទេ ប៉ុន្តែមានសាក្សី២រូបមកជាមួយធានាថាគាត់ជាខ្មែរ ហើយយើងក៏បានចុះឈ្មោះអោយហើយនេះគណបក្សនយោបាយគាត់នាំមក ដល់ចុះឈ្មោះអោយហើយគាត់មិនបោះឆ្នោតទេ គាត់ទៅបាត់នេះជាបញ្ហាដែរ។

ហើយកម្មវិធីចែកប័ណ្ណព័ត៌មាននេះ កន្លងមកអាជ្ញាធរមូលដ្ឋានគ្រប់សង្កាត់ខ្ញុំឃើញថា មានបញ្ហារកមើលមិនឃើញមិនដឹងគាត់ទៅណាទេ ហើយអាជ្ញាធរភូមិជួនកាលគាត់អត់ស្គាល់ទៀតឈ្មោះហ្នឹង ព្រោះគាត់នាំគ្នាគាត់មក៣នាក់និងសាមីខ្លួននិងចុះឈ្មោះអោយចុះឈ្មោះអោយគាត់ទៅបាត់ នេះជាបញ្ហា ហើយលើកក្រោយនេះខ្ញុំសូមថា សូមអោយមានវិសោធនកម្មកែដែរកន្លែងនេះ ខ្ញុំចង់អោយការចុះឈ្មោះ សូមអោយជនដែលមានទីលំនៅពិតប្រាកដនៅក្នុងឃុំសង្កាត់របស់ខ្លួនតែម្តងទៅ ដើម្បីជាសវាងចុះឈ្មោះទៅមានតែចំនួន។

ហើយបញ្ហាទី៣ ពាក់ព័ន្ធនឹងអត្តសញ្ញាណ ព្រោះខ្ញុំមើលនៅក្នុងប័ណ្ណព័ត៌មានដែលផ្តល់ជូនអ្នកបោះឆ្នោតនៅពេលខាងមុខនេះ យើងឈប់ប្រើហើយប័ណ្ណ៩៣-៩៨-២០០២ ខ្ញុំគិតថាបញ្ហានេះបើយើងប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសៀវភៅគ្រួសារ

ឬឯកសារផ្សេងទៀតដែលបានសរសេរនៅក្នុងប័ណ្ណព័តិមាន ខ្ញុំឃើញថាពលរដ្ឋនៅក្នុងសង្កាត់ខ្ញុំនេះ អ្នកខ្លះមិនទាន់មានសៀវភៅគ្រួសារទេ ហើយអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអត់ទាន់មានទេ អញ្ចឹងនៅពេលខាងមុខយើងត្រូវបោះឆ្នោតយកឯកសារណាមួយប្រាកដនោះ បងប្អូនអត់មានអញ្ចឹងការបោះឆ្នោតនោះគាត់មិនបានបោះទេ។ ជាអនុសាស្ត្ររបស់ខ្ញុំ សូមអោយមានការប្រើប័ណ្ណចាស់នោះខ្លះទៅ ព្រោះថាជួនកាលគាត់ធ្វើហើយ តែអត់ទាន់ដូចជាសៀវភៅគ្រួសារអីអ្នកខ្លះ៣ឆ្នាំហើយអត់ទាន់បានទេ បញ្ហានេះជាការព្រួយបារម្ភដែរ ជាសវាងដល់ថ្ងៃនោះគណបក្សនយោបាយថា កំលាំគាត់ម៉េចក៏មិនបានបោះ កំលាំគេម៉េចបានបោះ នេះជាបញ្ហាទៀត នេះជាបញ្ហារឿងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

ហើយបញ្ហាទី៤ បញ្ហាទំនាក់ទំនងព្រោះកន្លងមកគណបក្សនយោបាយគាត់មិនសូវមានទំនាក់ទំនងជាមួយអាជ្ញាធរប៉ុន្មានទេ។ គណបក្សផ្សេងៗគាត់ធ្វើការគាត់ទៅ ហើយអាជ្ញាធរមានការព្រួយបារម្ភដែរ។ ដូច្នេះខ្ញុំសូមថានៅពេលខាងមុខនេះនៅពេលដែលមានបញ្ហាអីសូមអោយគណបក្សនយោបាយមកនិយាយគ្នានៅលើតុ នៅអាជ្ញាធរមូលដ្ឋានតែម្តងពាក់ព័ន្ធរឿងអី ខុសរឿងអី យើងនិយាយគ្នា ហើយយើងនិយាគ្នាទៅសហការណ៍ទាំងអស់គ្នាទៅ បញ្ហាឃោសនានោះធ្វើម៉េច ? បញ្ហាកសាងកំលាំទៅធ្វើយ៉ាងម៉េច ? ដើម្បីយើងជាសវាងបញ្ហាទំនាស់គ្នាដែលយើងធ្វើខាងមុខ។ ព្រោះកន្លងមកគាត់ដើរខ្សិបគ្នាពេលយប់ ធ្វើអោយមានបញ្ហា អ្នកខ្លះឆក់ឱកាសដែរ ដូចជាពួកចោរអីវាទាក់ទងគ្នាលួចប្លន់ទៅ ធ្វើអោយមានការលំបាកដល់អាជ្ញាធរផងដែរ។

**លោក សុខ ចិត សមាជិកឃុំទួលនិមិត្ត** ខ្ញុំសូមលើកឡើងទាក់ទងនឹងការងារបោះឆ្នោត។ កន្លងមកខ្ញុំមិនទាន់ឃើញមានបញ្ហាទេ ក្នុងនាមខ្ញុំជាអ្នកសង្កេតការណ៍ ជាប្រធានអភិវឌ្ឍន៍ ក្នុងគណបក្សមួយ។ ដល់ពេលដែលប្រជាពលរដ្ឋចាប់ផ្តើមធ្វើការបោះឆ្នោតរើសមេភូមិថ្មី ក្នុងនាមខ្ញុំជាសមាជិកភូមិ ប្រជាពលរដ្ឋលោកអត់ដឹង ព្រោះថាពេលលោកឯងលើង លោកឯងលើង ដល់ពេលធ្លាក់អត់ដឹងលោកឯងធ្លាក់ផង ដូច្នេះខ្ញុំក៏អត់ទាន់មានគិតអីទេ ព្រោះកាលនោះខ្ញុំនៅតែចំការ ដូច្នេះគណបក្ស សម រង្ស៊ី លោកទៅអប់រំប្រជាពលរដ្ឋថ្ងៃមួយហើយប្រជាពលរដ្ឋគាត់បបួលគ្នាគាត់មក ហើយរាល់ដងមេភូមិហៅ មេភូមិក្នុងហ្នឹងខ្ញុំជាសមាជិកជាអនុប្រធានផងហៅប្រជាពលរដ្ឋមកប្រជុំមិនដែលបាន៤០-៥០គ្រួសារផង។ ដល់ពេលកើតបញ្ហាថ្ងៃទី២៧ ក្រោយគណបក្ស សម រង្ស៊ី គាត់បានបោះឆ្នោតរើសតំណាងគាត់រួចហើយ ខាងគណបក្សប្រជាជនលោកទៅបោះឆ្នោតដែរ មានតំណាងក្រុមប្រឹក្សានោះ២រូប តំណាងភូមិ១រូបទេ ២រូបនោះធ្លាក់បាត់ហើយ។

**លោក អ៊ូច ឌួក ចៅសង្កាត់រងទី២នៅសង្កាត់ទងរោង** ជាចំណាប់អារម្មណ៍ថ្ងៃបោះឆ្នោតខិតជិតមកដល់ ការទាក់ទងទៅនឹងអ្នកបោះឆ្នោត តាមភាពជាក់ស្តែងឃើញថា ការផ្តល់ព័តិមានដល់អ្នលបោះឆ្នោត ជាព័តិមានអ្នលបោះឆ្នោត ប៉ុន្តែភាពពិតសំរាប់អ្នកបោះឆ្នោតនៅពេលខាងមុខ ការផ្តល់ប័ណ្ណជាវិធីសាស្ត្រ គឺខ្ញុំមើលឃើញថាការផ្តល់ប័ណ្ណបណ្តើរ ហើយសូមអោយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ និងស្មៀនដែលជាសេនាធិការផ្នែករដ្ឋបាល ពិនិត្យឡើងវិញនូវគល់បញ្ជីប័ណ្ណ សូមអោយកែប្រែឈ្មោះរបស់គាត់អ្វីដែល គជប តម្រូវដូចជា អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ និងមានលិខិតបញ្ជាក់នេះវាជាចុងក្រោយទេ ក៏ប៉ុន្តែការធ្វើផ្តល់កន្ទុយប័ណ្ណនេះអ្នកដែលមានឈ្មោះបញ្ជីពី២០០២មកទល់សព្វថ្ងៃ ហើយលិខិតបញ្ជាក់ទីលំនៅវាជាចុងក្រោយ ប៉ុន្តែវិធីសាស្ត្រនេះគ្រាន់តែផ្តល់កន្ទុយប័ណ្ណបណ្តើរ សូមអោយស្មៀនឃុំសង្កាត់ដែលជាផ្នែករដ្ឋបាល និងក្រុមប្រឹក្សាឃុំសង្កាត់ត្រូវតែទទួលខុសត្រូវ ផ្តល់ប័ណ្ណបណ្តើរហើយត្រូវតែកែអ្វីដែល គជប និងក្រុមប្រឹក្សាឃុំសង្កាត់ទទួលស្គាល់ថា ពិត ដូចជាអត្តសញ្ញាណប័ណ្ណនេះមួយដែលពូមីងយកទៅបោះឆ្នោតនៅថ្ងៃទី០១ខែមេសាឆ្នាំ២០០៧ហ្នឹងបាន ដើម្បីថាអោយធានា ជាពិតប្រាកដរហូតដល់ថ្ងៃទី០១ខែតុលាដល់ថ្ងៃទី២០ខែតុលាឆ្នាំ២០០៦ហ្នឹងវានឹងបានល្អ តែកាលណាយើងធ្វើគៀកពេកគឺមិនល្អទេ នៅពេលនោះគឺប្រជាពលរដ្ឋគាត់នឹងសំរុកមកធ្វើ ដល់មកធ្វើទៅធ្វើមិនបានល្អ ធ្វើទៅជាន់គ្នាធ្វើមិនអស់ នេះជាវិធីសាស្ត្រមួយខ្ញុំសូមផ្តល់និងសូមសំណូមពរ ហើយធ្វើយ៉ាងណាអោយបានដល់អ្នក

បោះឆ្នោតបានពិប្រាកដធានា និងមានភាពសុក្រឹតហើយនិងមានទិន្ន័យល្អដល់សង្កាត់ផង ហើយនិងទិន្ន័យល្អដល់ គជប ផងពិព្រោះថ្នាក់ឃុំសង្កាត់នេះជាអ្នកធ្វើទិន្ន័យ ។

**លោក ឱក សេរី សោភក្តិ** ខ្ញុំសូមជម្រាបជូនបងស្រីប្រធានលេខាធិការដ្ឋានថា សំណើររបស់លោកគឺថាសូមអោយពេលយើងចែកប័ណ្ណគឺបើមានខុសសូមអោយយើងធ្វើការកែបណ្តើរឆ្លៀតពេលចំនេញនេះ ។ តើអ្នកបងធ្វើបានយ៉ាងណាក្នុងការធ្វើសហប្រតិបត្តិការណ៍រវាងលេខាធិការដ្ឋានជាមួយស្មៀនឃុំសង្កាត់ ជាពិសេសស្មៀនឃុំសង្កាត់ហ្នឹង ?

**លោក ផាន់ ពេជ្រ ប្រធានមន្ទីកសិកម្មក្រុងប៉ៃលិន** ខ្ញុំសូមមានចំណាប់អារម្មណ៍ទៅលើលទ្ធិប្រជាធិតេយ្យ នៅក្នុងការបោះឆ្នោតខាងមុខនេះ ។ ថាអ្វីទៅដែលហៅថាលទ្ធិប្រជាធិតេយ្យ ? លទ្ធិប្រជាធិតេយ្យមិនមែនមានតែសង្គមស៊ីវិលនោះទេ ជាក់ស្តែងក្រុងប៉ៃលិននេះហៅថាសមាហរណកម្ម គឺកងទ័ពអ្នកធ្វើ បើគ្មានប្រជាធិតេយ្យក្នុងចំណោមកងទ័ពទាំងអស់នោះទេ មិនអាចសមាហរណកម្មនៅទីនោះបានទេ នេះទី១ ។ ទី២ អ្វីដែលហៅថាលទ្ធិប្រជាធិតេយ្យ ? គឺជាការគោរពច្បាប់ មិនមែនតាមអំពើរចិត្តរបស់បុគ្គលម្នាក់ៗនោះបានទេ ។

**លោក ឱក សេរី សោភក្តិ** ខ្ញុំបាទសូមអរគុណជាមួយលោក ផាន់ ពេជ្រ ប្រធានមន្ទីកសិកម្ម ។ ហើយដែលខ្ញុំបាទគោរពស្រលាញ់យន្តការឧប៉សែលនេះគឺដោយសារបានឮសំដីអញ្ចឹង បានឮសំដីត្រង់ទៅត្រង់មករវាងលោកសុមេទ្ធ និងលោកពេជ្រ គាត់ឆ្លើយខ្ញុំបាទនៅពេលឃើញអញ្ចឹងកើតឡើង ហើយដោយសន្តិវិធី ដោយសេចក្តីថ្លៃថ្នូរ ដោយការយោគយល់គ្នាបែបនេះខ្ញុំបាទគិតថាប្រទេសរបស់យើងនេះហើយដែលយើងអនុវត្តលទ្ធប្រជាធិតេយ្យពិតប្រាកដ ។

**លោក តាន់ សាវ៉ាត អភិបាលរងខ័ណ្ឌសាលាក្រៅប៉ៃលិន** ខ្ញុំសូមសំណូមពរថា គ្រប់គណបក្សនយោបាយទាំងអស់ដែលបានមកប្រជុំនៅក្នុងពេលនេះគឺយើងត្រូវសាមគ្គីគ្នា ព្រោះសង្គ្រាមយើងធ្វើច្រើនទសវត្សមកហើយ ។ បញ្ហាទី២ គឺថាគ្រប់គណបក្សនយោបាយទាំងអស់ត្រូវទំនាក់ទំនងគ្នា បើយើងមិនទំនាក់ទំនងគ្នាទេ ចាំតែហែកហួរគ្នាទេ ដូច្នេះទឹកដីយើងអស់ហើយ នៅខាងកើតអស់ប៉ុន្មាន នៅខាងលិចអស់ប៉ុន្មាន ហើយឥឡូវយើងនៅសល់ប៉ុន្មាន ? បើខ្ញុំបាទនិយាយទៅខុសឆ្គងក៏សូមអព្យាស្រ័យ នេះយើងត្រូវតែទំនាក់ទំនងគ្នា ឧទាហរណ៍ថាឮបញ្ហាអីយើងត្រូវរត់រកគ្នា យើងមកទីនេះសិតតែជាថ្នាក់ដឹកនាំ អញ្ចឹងថ្នាក់ដឹកនាំនេះទី១ គឺធនធានខាងអក្សរសាស្ត្រ ទី២ អង្គសិក្ខាសាលាកន្លែងណាគឺយើងបានចូលរួមទាំងអស់ ហើយក៏រិតនៃការយល់ដឹងរបស់យើងគឺមានក៏រិតដែរ ប៉ុន្តែបើប្រជាជនយើងមិនទាន់យល់ យើងនិយាយអញ្ចេះ គាត់ទៅថាអញ្ចុះ នេះហើយនាំអោយមានការបែបបាក់គ្នា នេះសូមមេត្តាអព្យាស្រ័យ ។ ហើយជាសវាងការហែកហួរគ្នា ហើយប្រតិកម្ម ឧទាហរណ៍ថាគ្រាន់តែឮ យើងក្នុងឋានៈដឹកនាំគណបក្សនិមួយៗយើងប្រតិកម្ម យើងអត់មានរត់មករកអង្គប្រជុំ យើងមិនរត់មករកគ្នាដោះស្រាយ តើយើងដោះស្រាយចេញទេ ? យើងដឹងឮទេ ? ប៉ុន្តែនៅក្នុងអង្គប្រជុំយើងមិនបាននិយាយផង លើតុយើងអត់មានដាក់ថាអោយវាឃើញថាពាក្យថាតម្លាភាព យើងបែរទៅនិយាយក្រោមតុ ហើយចេញទៅវិញយើងនិយាយក្រោយខ្នង ចំនុចនេះចំនេញឬខាត ? ច្បាស់ជាខាត ច្បាស់ជាទឹកដីរបស់យើងទៅអណាគតមិនដឹងទៅជាយ៉ាងម៉េចទេ ព្រោះសង្គ្រាមយើងមានយូរហើយ ។

បញ្ហាទី៣ គឺសូមអោយលោកស្រីបង្កើតការប្រជុំអោយបានទៀងទាត់ គឺអញ្ជើញគ្រប់គណបក្សទាំងអស់មកប្រជុំ សូមរបាយការណ៍តាមគណបក្សនិមួយៗ មានបញ្ជីឈ្មោះត្រឹមត្រូវហើយឬនៅ ឬនៅក្នុងភូមិរបស់យើងប្រជាជន យើងនិយាយគ្នាយ៉ាងម៉េចៗ យើងត្រូវតែមានអោយច្បាស់លាស់ មានប័ណ្ណអោយច្បាស់លាស់ ហើយពេលវេលាយើងថាយូរគឺអត់យូរទេ ព្រោះលោកស្រីគាត់បានជម្រាបហើយថា ទៅអត់ជួបគាត់ព្រោះគាត់នៅចំការ ឬនៅស្រែ នេះធ្វើអោយខាតពេលវេលាណាស់ ។ ហើយសូមអោយគណបក្សទាំងអស់កុំប្រតិកម្មនោះគឺថា យើងឮហើយយើងគិតហើយបានយើងធ្វើ ។ ឧទាហរណ៍ថាឮ សមាជិកយើងនិយាយយ៉ាងម៉េចៗនោះ

យើងត្រូវយកមកគិត ហើយបានយកមកធ្វើ។ បើយើងគ្រាន់តែឮហើយយើងចាប់ផ្តើមខឹង ភ្លាមហើយប្រជាជនធម្មតាទេមកពីហាត់ផងខឹងដែរ ។

**លោក ឱក សេរី សោភក្តិ៍** ខ្ញុំសូមអរគុណលោក សារ៉ាត អត្ថន័យហ្នឹងខាងឧប់សែលសូមទទួលឯកភាពពេញទីតែម្តង។ ខ្ញុំបាទនឹងអញ្ជើញលោកស្រីអៀង សុភី មានប្រសាសន៍ទៅលើប្រសាសន៍លោក សារ៉ាត ស្នើរអោយមានការប្រជុំនោះទៀងទាត់ តាមខ្ញុំបានស្តាប់ខាងបងស្រីថាមានការប្រជុំនេះរាងរាល់អាទិត្យ តែបងថាសូមអោយទៀងទាត់ ប្រហែលជាមិនបានទៀងទាត់ ឬមួយក៏យ៉ាងម៉េចចាំបងស្រីលោកបកស្រាយ ។

**លោក ឈុន ចាន់ដា ក្រុមប្រឹក្សាគណបក្ស សម រង្ស៊ី ក្រុងប៉ៃលិន** ខ្ញុំមានចំណាប់អារម្មណ៍ ៣ ពាក់ព័ន្ធនឹងការបោះឆ្នោត។ ចំនុចទី១គឺ ការចុះឈ្មោះបោះឆ្នោត ចំនុចទី២ សន្តិសុខ ចំនុចទី៣ និងការិយាល័យបោះឆ្នោត។ ហើយចំនុចទាំង៣នេះ បើសិនជាយើងរកមធ្យោបាយណាមួយ ឬរកអ្វីមួយដោះស្រាយចំនុចទាំង៣នេះបាន គឺដំណើរការបោះឆ្នោតប្រក្របដោយលទ្ធិប្រជាធិតេយ្យនិងត្រឹមត្រូវពិតប្រាកដ។ ខ្ញុំគិតថាការចុះឈ្មោះបោះឆ្នោតធ្វើតាំងពី៩៨រហូតមកដល់ពេលបច្ចុប្បន្ននេះ គឺប្រជាពលរដ្ឋខ្មែរយើងមិនបានធ្វើការចុះឈ្មោះសព្វគ្រប់គ្រួសារទេ ព្រោះប្រជាពលរដ្ឋយើងច្រើនតែប្តូរទីលំនៅ នេះខ្ញុំក៏ឯកភាពមួយដែរ ប៉ុន្តែការចុះឈ្មោះបោះឆ្នោតនេះវាពាក់ព័ន្ធច្រើន ដូចពី២០០៣-៩៨អញ្ចឹងដែលយើងដឹងថាវាមានពាក់ព័ន្ធនិងនិន្នាការនយោបាយ ជួនកាលគេដឹងថាអ្នកនេះខាង ក ខាង ខ ទៅគេអត់ចុះឈ្មោះអោយក៏មានដែរ។ ប៉ុន្តែពេលនេះមានប្រជាពលរដ្ឋនៅក្រុងប៉ៃលិនយើងមួយចំនួនគាត់មកនៅពិតប្រាកដ ហើយអត់មានរើទៅណាទេ ហើយនៅក្នុងសង្កាត់ប៉ៃលិន ខ្ញុំលើកត្រង់ៗទៅកន្លែងណាខ្ញុំនាំទៅភ្លាម គ្នាចង់ណាស់ចង់មានសៀវភៅលឿងចង់មានប័ណ្ណបោះឆ្នោត ចង់មានសៀវភៅគ្រួសារ នេះនិយាយរឿងពាក់ព័ន្ធនិងអ្នកធ្វើ អ្នកធ្វើវាផ្ទុយនិងអ្នកថា អ្នកថាយ៉ាងម៉េច អ្នកថាគឺក្រុមប្រឹក្សាសង្កាត់ គណបក្សនយោបាយជាអ្នកថា ធ្វើអត្តសញ្ញាប័ណ្ណ ធ្វើសៀវភៅគ្រួសារ តែអ្នកធ្វើគឺលោកប៉ូលិសអ្នកធ្វើ អញ្ចឹងវាមានការផ្ទុយគ្នា ព្រោះពេលឃោសនាគណបក្សនយោបាយឃោសនាថា បើបោះឆ្នោតអោយខ្ញុំអត់យកលុយទេ តែដល់ចុះធ្វើប៉ូលិសអ្នកធ្វើទេតើ មិនមែនលោកចៅសង្កាត់អ្នកធ្វើឯណា ដល់ប្រជាពលរដ្ឋទៅធ្វើគេថា ប័ណ្ណលឿងមួយ១០០បាត ខ្ញុំថាខ្ញុំអត់មាន ១០០បាតផងបង ហើយបើអត់១០០បាតអត់ធ្វើអោយ សៀវភៅគ្រួសារមួយ១០០បាត ឥឡូវចុះធ្វើអត្តសញ្ញាប័ណ្ណទៀតហើយ ខ្ញុំឮថាលោកស្នងការរងប្រាប់ថាអត់យកលុយទេប្អូនឥឡូវនេះ ប៉ុន្តែមិនមែនលោកទៅធ្វើឯណាកូនចៅទៅធ្វើ នេះចំនុចនេះ១ អញ្ចឹងដូចជាការចុះឈ្មោះបោះឆ្នោតអញ្ចឹង ក្រុមប្រឹក្សាសង្កាត់និងស្មៀនឃុំសង្កាត់ទៅចុះទៅ សួរថាបងឯងមានសៀវភៅគ្រួសារឬអត់ ថាអត់ តែខ្ញុំរស់នៅទីនេះពិតប្រាកដ តែគាត់មិនបានចុះទេអាណ្ណឹងវារាំងស្ទះមួយដែរ។

ទី២ពាក់ព័ន្ធនិងសន្តិសុខ ខ្ញុំតែងតែយកចិត្តទុកដាក់ដែរ រឿងបញ្ហាសន្តិសុខនៅពេលបោះឆ្នោតម្តងៗ ព្រោះនៅ២០០៣កាលពីបោះឆ្នោតជាតិនេះ ខ្ញុំបានសង្កេតឃើញហើយដូចនៅចំនុចសាលព្រហ្ម ស្ថានីយ៍បោះឆ្នោតច្បាប់គេមានឃាត់ហើយសន្តិសុខ ឧទាហរណ៍សន្តិសុខស្ថានីយ៍បោះឆ្នោតគឺ៥០ម៉ែត្រពីស្ថានីយ៍បោះឆ្នោត ប៉ុន្តែពេលបោះឆ្នោតមានអញ្ចឹងឯណាគឺទៅឈរនៅការិយាល័យបោះឆ្នោតនោះតែម្តង នេះវាខុសនឹងនីតិវិធីច្បាប់ បើអញ្ចឹងច្បាប់ចែងមកធ្វើស្អី ? ដូច្នេះអស់លោកជាបណ្តាលកងកំលាំងពាក់ព័ន្ធនិងជាអ្នកការពារសន្តិសុខដល់ស្ថានីយ៍បោះឆ្នោតគួរតែគោរពតាមនីតិវិធីរបស់យើង ទៅតាមគោលការណ៍ដែលយើងប្រកាន់ខ្ជាប់រួចមកហើយនេះថាយើងជាអ្នកគោរពច្បាប់ ជាអ្នកការពារផលប្រយោជន៍ជូនប្រជាពលរដ្ឋ ដូច្នេះកុំយកតួនាទីរបស់យើងទៅគំរាមកំហែងទៅបន្លាចប្រជាពលរដ្ឋ។

ចំនុចទី ៣ ពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោត ខ្ញុំគិតថាការិយាល័យបោះឆ្នោតយើងពីមុនមាន៤២ តែឥឡូវដូចអ្នកស្រីប្រធានបានលើកឡើងគាត់នឹងលើកដល់៥៣ទូទាំងក្រុងប៉ៃលិន ប៉ុន្តែទោះបីជាមានការិយាល័យបោះឆ្នោតលើស១១ទៀតក៏ដោយ ក៏ខ្ញុំជឿថា

នៅក្រុងប៉ៃលិននៅលំបាកដល់ប្រជាពលរដ្ឋក្នុងការបោះឆ្នោតដដែរ។ ព្រោះខ្ញុំយល់ថាភូមិសាស្ត្រនៅតំបន់ប៉ៃលិនយើងនេះ ប្រជាពលរដ្ឋជាអ្នកចំការហើយគាត់នៅក្នុងព្រៃឆ្ងាយណាស់ជូនកាលគាត់មកបាន ជូនកាលគាត់មកមិនបាន ដូច្នេះខ្ញុំគិតថាការិយាល័យបោះឆ្នោតនេះយើងគួរតែ បង្កើតការិយាល័យបោះឆ្នោតចល័តបន្ថែមទៀត ដើម្បីជួយសំរួលដល់បងប្អូននៅក្នុងជនបទ នៅក្នុងព្រៃជ្រៅ។ ហើយការិយាល័យបោះឆ្នោតនេះយើងធ្លាប់មានបទពិសោធន៍កាលពីសម័យអ៊ុនតាក់ដែលកាលពីឆ្នាំ១៩៩៣នោះ អញ្ចឹងយើងអាចមានគណៈកម្មាធិការយើងចុះទៅរហូតតាមដានអញ្ចឹងដូចអ៊ុនតាក់អញ្ចឹង នេះការិយាល័យបោះឆ្នោតចល័ត។ ហើយនៅក្នុងហ្នឹងក៏យើងពិនិត្យដែរថាបងប្អូនមានអត្តសញ្ញាណប័ណ្ណឬអត់ ថាមាន នៅសង្កាត់ណា ? នេះចំនុចទី១ អញ្ចឹងយើងបោះនៅក្នុងហឹបនៅក្នុងសង្កាត់ហ្នឹង វាមានហឹបតាមសង្កាត់របស់គេ នេះពាក់ព័ន្ធការិយាល័យបោះឆ្នោត តែខ្ញុំសូមស្នើរមួយទៀតចំពោះការិយាល័យបោះឆ្នោតដដែល ឧទាហរណ៍បើយើងកុំដាក់កំណត់ក្នុងការិយាល័យមួយ ៧០០នាក់បានឬអត់ ? ឧទាហរណ៍ក្នុងសង្កាត់ទួលល្វា ទឹកដីសង្កាត់ទួលល្វា ឬក៏សង្កាត់ស្ទឹងកាច់ ជូនកាលសង្កាត់ស្ទឹងកាច់ រហូតដល់អូរតាលី អូរតាទឹម ឯណានោះស្រាប់តែត្រូវបោះនៅព្រហ្មងណោះឈ្មោះ មកអត់ទាន់ ហើយបោះនៅក្នុងក្រុមប្រឹក្សាសង្កាត់ អញ្ចឹងខ្ញុំគិតថាក្នុងផ្ទៃដីរបស់សង្កាត់នេះអ្នកដែលមានអត្តសញ្ញាណប័ណ្ណរស់នៅក្នុងសង្កាត់ស្ទឹងកាច់អាចបោះឆ្នោតបានឬអត់នៅក្នុងទឹកដីរបស់ស្ទឹងកាច់ហ្នឹង? ព្រោះរើសរកតែមេឃុំទេ ដល់យើងបោះអោយក្នុងសង្កាត់ហ្នឹង តើយើងអាចបោះបានឬអត់នេះជាសំណួមពររបស់ខ្ញុំ យើងគួរតែបោះបាន យើងធ្វើដូចអ៊ុនតាក់អញ្ចឹង បោះតំណាងរាស្ត្រនៅខេត្តតាកែវ អ្នកឯងបោះបានបោះនៅកន្លែងណាក៏បានដែរ នេះគឺជាយុត្តិវិធីមួយស្រួល សំរួលដល់ប្រជាពលរដ្ឋរបស់យើងដែលមានការលំបាកក្នុងការធ្វើដំណើរ យើងដឹងហើយជូនឡានមកហើយទំរាំរកឈ្មោះឃើញអត់ងាយរកទេឈ្មោះ បើអញ្ចឹងគ្រាន់តែមានអត្តសញ្ញាប័ណ្ណមួយថា អ្នកឯងនៅសង្កាត់ស្ទឹងកាច់ បោះឆ្នោតបានបាត់នៅសង្កាត់ស្ទឹងកាច់ ឬអ្នកណាក៏បានដែរនេះជាគំនិតរបស់ខ្ញុំ ប៉ុន្តែខ្ញុំសូមស្នើរទៅលោកស្រីប្រធានលេខាធិការដ្ឋានមេត្តាពិនិត្យហើយនិងឯកឧត្តមអភិបាលក្រុងជួយពិចារណារឿងករណីនេះ ដើម្បីសំរួលការបោះឆ្នោតជូនបងប្អូនប្រជាពលរដ្ឋទៅថ្ងៃអាណាគត។

**លោក ហ៊ុយ ម៉ាំង មកពីអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍** ខ្ញុំមានសំនួរនិងអនុសាស្ត្រពីរបីចំនុចទាក់ទងនឹងការបោះឆ្នោត។ ទាក់ទងនិងលោកស្រីប្រធានលេខាធិការដ្ឋានមានប្រសាសន៍ថា ការចុះឈ្មោះក្នុងការបោះឆ្នោតមានភាពខុសគ្នា វាមិនមានតម្លាភាពចង់និយាយថាបើចុះឈ្មោះ១០០នាក់បោះបានតែ៨០នាក់ មូលហេតុគាត់ថាទៅថៃមកពីថៃមិនទាន់ ខ្ញុំចង់សួរថា ចំនុចនេះវាមានការគំរាមកំហែង ឬមកពីគាត់មិនពេញចិត្តក្នុងការបោះឆ្នោត ? សូមអោយលោកស្រីប្រធានលេខាធិការដ្ឋានស៊ើបអង្កេតបញ្ហានេះជាចំនុចខ្វះខាតមួយសួរថាមូលហេតុអីដែលវាមានការខ្វះខាតចំនុចហ្នឹង ? ហើយជាអនុសាសន៍ ដូចបងៗគាត់លើកឡើងពីបញ្ហាគណបក្សនិងការជជែកគ្នាអំពីចំនុចនៃការគំរាមកំហែង ពីការររអើង ពីការប្រកាន់បក្សពួក និន្នាការផ្សេងៗក្នុងក្រុងប៉ៃលិននេះ មិនមែនតែក្រុងប៉ៃលិនទេ នៅបណ្តាល២៤ខេត្តក្រុងនេះមានទាំងអស់នូវរាល់ចំនុចដែលបងៗលើកឡើងនេះ ខ្ញុំសូមផ្តល់ជាអនុសាសន៍ទៅដល់ គជប ហើយអង្គការសង្គមស៊ីវិល វាមានភាពងាយស្រួលដែលឥឡូវលោកខាងស្នងការគាត់ បងបានចូលរួមដែលទាក់ទងបញ្ហានេះ យើងធ្វើការស៊ើបអង្កេតអោយអង្គការធ្វើការប្រជុំទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន គឺធ្វើការស៊ើបអង្កេតទៅលើការរំលោភសិទ្ធិមនុស្ស។ ការរំលោភសិទ្ធិមនុស្សនេះចង់និយាយថា គាត់បញ្ចេញមតិក្នុងការនិយាយ ក្នុងការចូលចិត្តអីមួយ គាត់បាត់បង់សេរីភាពនោះ អញ្ចឹងវាអត់មានតម្លាភាពទេក្នុងការបោះឆ្នោតនោះទី១។ ទី២ ធ្វើការស៊ើបអង្កេតទៅលើការគំរាមកំហែង បើសិនមានការគំរាមកំហែង ខ្ញុំយល់មិនច្បាស់ទេបើ គជប មានចែងនៅក្នុងមាត្រាណាមួយនិយាយពីច្បាប់ ទោស លុយ ឬព្យួរ ឬដកតំណែង មានភាពងាយស្រួលទេ យើងមានគណៈកម្មាធិការស៊ើបអង្កេតមួយ ស៊ើបថាបុគ្គលនេះគំរាមកំហែងបុគ្គលនេះ យើងស្រួលរកយើងដាក់ទោសគាត់ពិន័យប៉ុន្មានឆ្នាំ

លុយប៉ុន្មាន ហើយព្យួរការងារគាត់ ឬដកតំណែងនេះជាការងាយស្រួលរបស់ គជប ហើយបងប្អូនជដែកនេះវាជាពិធីរបស់ គជប អ្នកចែងអោយ ហើយបងប្អូនជដែកគ្នាវាជាព័ត៌មានមួយសំរាប់ផ្តល់ជូនទៅ គជប សំរាប់រៀបចំអោយបានប្រសើរឡើង។

ទី៤ ខ្ញុំចង់សួរថា តើមានច្បាប់ចែងអោយដែលឬអត់ គជប ទាក់ទងនឹងច្បាប់បោះឆ្នោតនេះ ? បើមានចែងពីទោស ពីលុយ ឬព្យួរ ឬដកតំណែងវាមានភាពងាយស្រួលដល់បងប្អូនសំរាប់ការអនុវត្តទេ។ អញ្ចឹងការរអើងក៏អត់មាន ការប្រកាន់បក្សពួកក៏អត់មាន ការគំរាមកំហែង ការរំលោភសិទ្ធមនុស្សក៏អត់មាន បើវាមានចែងចំនុចទាំង៤នេះ វាមានការងាយស្រួល ដាក់ទោស១០ឆ្នាំ ២០ឆ្នាំ ឬដកតំណែងគាត់ថ្នាក់ណាក៏ដោយងាយស្រួលព្រោះចំនុចអស់នេះវាមានតាំងពីឆ្នាំ១៩៩៣មក រហូតមកដល់ឥឡូវនេះ។

**លោក នាក់ ណាង អនុប្រធានមន្ទីការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្រុងប៉ៃលិន** ខ្ញុំសូមលើកបញ្ហាមួយចំនួនពាក់ព័ន្ធនិងគណៈកម្មាធិការរៀបចំការបោះឆ្នោត។ ខ្ញុំមានបញ្ហាមួយចំនួន ទី១ ពាក់ព័ន្ធនិងគណបក្សនយោបាយ គណបក្សនយោបាយមួយចំនួននៅពេលដែលបានទទួល ឬឮនូវលទ្ធផលបណ្តោះអាសន្នតែងតែចោទថា គណៈកម្មាធិការរៀបចំការបោះឆ្នោតមិនមានភាពសុក្រឹត ឬមិនមានភាពយុត្តិធម៌ បើតាមខ្ញុំធ្លាប់សង្កេតនិងធ្លាប់ចូលរួមនៅក្នុងការងារនេះ ទោះបីថា សមាជិក សមាជិការ ឬក៏ប្រធានគណៈកម្មាធិការរៀបចំការបោះឆ្នោតដែលមាននិន្នាការទៅរកគណបក្សនយោបាយណាមួយក៏ដោយ គឺមិនអាចអនុវត្តប្រាសចាកពីនីតិវិធីច្បាប់ដែល គជប ចែងទេ ដូច្នេះសូមអោយយើងយល់ទាំងអស់គ្នា។ ឧទាហរណ៍ដូចជាលទ្ធផលនៃការរាប់សន្លឹកឆ្នោត ការអោយសុពលភាពទៅលើសន្លឹកឆ្នោតដែលបានការ កន្លងមកមិនមែនខ្ញុំបន្ទោសទៅលើភ្នាក់ងារសង្កេតការណ៍របស់គណបក្សទេ ប្រហែលជាគាត់យល់បញ្ហានេះមិនបានស៊ីជម្រៅ បើតាមខ្ញុំគិត គាត់យល់នីតិវិធីនៃការបោះឆ្នោតមិនបានស៊ីជម្រៅ ដូចការគូសវាសសន្លឹកឆ្នោត ហើយច្បាប់បោះឆ្នោតកំណត់ហើយថាសញ្ញាឌិច ដែលកំណត់បំរើអោយឆន្ទៈនៃសន្លឹកឆ្នោតបានការនោះគេចាប់គូសពីណាទៅ ហើយចំនុចណាគេយកជាបានការបាន ហើយច្បាប់មួយទៀតចែងថា កាលណាសន្លឹកឆ្នោតដែលយកជាបានការគឺសន្លឹកឆ្នោតដែលគូសចំក្រឡោនដែលបំរើអោយគោលដៅ អញ្ចឹងអ្នកខ្លះគាត់គូសទៅចុងកន្ទុយជាប់បន្តិច នេះខ្ញុំឧទាហរណ៍ទេ ព្រោះវាជារឿងជាក់ស្តែង ដូច្នេះនៅពេលដែលគណៈកម្មាធិការការិយាល័យបោះឆ្នោត នៅពេលដែលរាប់ផ្តល់សុពលភាព បានន័យថាផ្តល់សន្លឹកឆ្នោតហ្នឹងចាត់ទុកជាសន្លឹកឆ្នោតបំរើអោយឆន្ទៈពីអ្នកបោះសម្រេចថាយកជាប់ គណបក្សគាត់ថាលោកឯងហ៊ានអីបានសម្រេចថាអោយអាហ្នឹងបានការ ប៉ុន្តែការពិតគាត់យល់មិនស៊ិជម្រៅទេអ្នកសង្កេតការហ្នឹង ។

បញ្ហា១ទៀត រឿងការរាប់សន្លឹកឆ្នោត ការរាប់សន្លឹកឆ្នោត នីតិវិធីនៃការរាប់គេអោយរាប់ ១ដុំ ដាក់២៥ កាលណារាប់ធម្មតាវាមានស្ទាប់សន្លឹក រាប់ម្តង បីរដង វាមានស្ទាប់ អញ្ចឹងគាត់ចោទថាម៉េចក៏លិចចេញសន្លឹកឆ្នោតមួយសន្លឹកទៀតមកពីណា ? នេះជារឿងជាក់ស្តែង។ ប៉ុន្តែបើច្បាប់បោះឆ្នោតគេអាចយកលទ្ធផលនៃច្បាប់បោះឆ្នោតនេះជាផ្លូវការបាន កាលណាសន្លឹកឆ្នោតលំអៀង ១សន្លឹក គេមិនយកជាការទេ តែយើងនឹងព្យាយាមធ្វើអោយសុក្រឹត ប៉ុន្តែការរាប់វាមានការភាន់ច្រឡំខ្លះ ប៉ុន្តែក្រោយមកយើងក៏បានរកឃើញ។

បញ្ហាទី២ ខ្ញុំសូមលើកពីការរអើងនៅក្នុងគណបក្សនយោបាយបន្តិចចុះ យើងត្រូវយល់ថាយើងជាខ្មែររស់នៅលើទឹកដីរបស់ខ្មែរ អញ្ចឹងយើងគោរពតែមានឆន្ទៈមនះសិកាដូចគ្នាខ្មែរដូចគ្នា យើងគិតថាគណបក្សណាក៏ដូចគណបក្សណាដែរ បំរើផលប្រយោជន៍ជាតិទាំងអស់គ្នា គ្រាន់តែផ្លូវដើរផ្សេងគ្នាទេ អញ្ចឹងបើឃើញបុគ្គល ក ប្រកាន់យកមនោគមវិច្ឆលទ្ធិគណបក្សផ្សេងសូមកុំស្អប់កុំរអើងគាត់ ព្រោះគណបក្សគេប្រឆាំងគ្នាមិនមែនប្រឆាំងដូចយើងអ្នកនៅតូចតាចនេះទេ ខ្មែរយើងប្រឆាំងគ្នាច្រើន តែយកស្លាប់រស់បក្សពួកសត្រូវស៊ីសាច់ គេមិនដែលធ្វើអញ្ចឹងទេ កាលណាលទ្ធិប្រជាធិតេយ្យគឺគេប្រឆាំងគ្នាទៅលើមនោគមឬក៏កម្មវិធី នយោបាយរបស់គណបក្ស

និមួយៗ គណបក្ស ក កម្មវិធីនយោបាយរបស់ខ្លួនធ្វើអញ្ចេះ គណបក្ស ខ កម្មវិធីនយោបាយរបស់ខ្លួនធ្វើអញ្ចុះទៅ គេគ្រាន់តែប្រឆាំងគ្នាអញ្ចឹងទេ ប៉ុន្តែគេមិនដែលប្រឆាំងគ្នាក្នុងលក្ខណៈជាឃាមជ័រទេ។

ពាក់ព័ន្ធនឹងសំនួរទី៣ ពីរឿងអ្នកសង្កេតការគណបក្ស។ អ្នកសង្កេតការគណបក្សរបស់គណបក្សហ្នឹង សូមថារើសអ្នកសង្កេតការអោយមានសមត្ថភាពបន្តិចទៅ ព្រោះគាត់អ្នកសង្កេតការណ៍ប្រៀបបីដូចជាប៉ូលីសអញ្ចឹង គាត់ចង់ទៅឃ្លាំងមើលការងារបោះឆ្នោរសួរថាការងារបច្ចេកទេសការបោះឆ្នោតនោះគាត់ចេះឬទៅ ? បើគាត់ចេះអត់ដល់អ្នកធ្វើផង ធ្វើម៉េចគាត់ទៅចាប់គេបាន ? នេះសូមអោយខាងគណបក្សគិតគូរអោយមែនទែន។ អញ្ចឹងរាល់ភ្នាក់ងារអ្នកសង្កេតការគណបក្សទាំងអស់ធ្វើការអប់រំគាត់ មាននីតិវិធីបោះឆ្នោតអោយគាត់យល់អោយបានច្រើន ជាសវាងបញ្ហាព្រោះកន្លងមកបញ្ហាវាកើតចេញពីបន្តិចៗនេះ វាមិនមានចើនទេ ។ ហើយជាក់ស្តែងលទ្ធផលការងារបោះឆ្នោតកន្លងមក គឺថាលទ្ធផលដែលយើងអាចទទួលយកបានប្រកបដោយមោទនភាពណាស់ ថ្វីត្បិតតែយើងមានកំហុសតែកំហុសតិចតួច។

បញ្ហាទី៤ ការលើកផ្លាក់ ។ នេះពាក់ព័ន្ធនឹងអាជ្ញាធរ ព្រោះវាមានរឿងច្រើនដល់ការងារបោះឆ្នោតព្រោះនៅក្នុងច្បាប់គេចែងហើយគណបក្សដែលបានចុះបញ្ជីបោះឆ្នោតដែលបានចូលរួមបោះឆ្នោត មានសិទ្ធធ្វើសកម្មភាពលើកផ្លាក់ឃោសនានៅក្នុងទឹកដីរបស់ខ្លួនដោយមានការយល់ព្រមពីអាជ្ញាធរមូលដ្ឋាន ។ ហើយកន្លងមកច្រើនតែមានបញ្ហា គណបក្សខ្លះថាលើកផ្លាក់ហើយបាត់ផ្លាក់វាជាក់ស្តែងមែនបាត់មែន អញ្ចឹងសូមថាអាជ្ញាធរមូលដ្ឋានកុំរអើង គ្រាន់តែផ្លាក់សញ្ញា គ្រាន់តែជាការសម្គាល់គណបក្សមួយវាមិនមានផលប៉ះពាល់អីធ្ងន់ធរទេ អញ្ចឹងសូមអោយយោគយល់គ្នាកុំអោយបញ្ហានេះកើតឡើង។

បញ្ហាទី៥ ពាក់ព័ន្ធនឹងរឿងធ្វើអត្តសញ្ញាណប័ណ្ណ។ ជាក់ស្តែងរូបខ្ញុំផ្ទាល់ធ្លាប់ឮថាអត្តសញ្ញាណប័ណ្ណខុសអក្ខាវិរុទ្ធ ឬក៏ខូចហើយតែកាលណាសូមធ្វើម្តងទៀតគាត់ទារ ៥ម៉ឺនរៀល ហើយខ្ញុំចង់ដឹងថា តើក្រសួងមហាផ្ទៃ មានច្បាប់កំណត់ថាកាលណាអត្តសញ្ញាណប័ណ្ណខុស ឬបាត់ ឬខូច តើច្បាប់មានថាការធ្វើជាលើកទី២នេះ តើកំណត់អោយយកលុយមែនអញ្ចឹងមែនឬអត់ ? ព្រោះនេះវាពាក់ព័ន្ធនឹងការងារបោះឆ្នោតដែរ ។ ព្រោះលទ្ធភាពប្រជាពលរដ្ឋនៅក្រុងប៉ៃលិនយើងដឹងហើយ ភាគច្រើនជាអ្នកធ្វើចំការហើយជីវភាពក៏នៅខ្សត់ខ្សោយដែរ បើកាលណាច្បាប់បោះឆ្នោតកំណត់ថា យកអត្តសញ្ញាណប័ណ្ណជាឯកសារសំរាប់បោះឆ្នោត ព្រោះប្រជាជនក្រុងប៉ៃលិនភាគច្រើនណាស់នៅមិនទាន់បានធ្វើ ដោយមូលហេតុបញ្ហារឿងលុយកាក់ហ្នឹងឯង យើងមិនចោទថាស្ថាប័ណពុករលួយទេច្បាប់វាមានហើយ ច្បាប់វាមកល្អហើយគ្រាន់តែប្រតិបត្តិករមិនដឹងជាយ៉ាងម៉េច ?

**លោក ឱក សេរី សោភ័ក្តិ** ខ្ញុំបាទសូមអរគុណ ចំនុចទី៣ដែលលោកណាង បានមានប្រសាសន៍ឡើងថា បញ្ហារឿងអ្នកសង្កេតការណ៍ដែលជាតំណាងគណបក្សនយោបាយនោះ តាមដែលខ្ញុំដឹងបញ្ហានេះល្អណាស់ ហើយសំខាន់។ ហើយនៅក្នុងឧបសែលនេះយើងបានទាមទារច្រើនខែ ទាល់តែ NEC នោះលោកបានសម្រេចហើយថា នឹងមានការបើកការបំពាក់បំប៉នរួមគ្នាតែម្តង រវាងមន្ត្រីរបស់ NEC គ្រប់ជាន់ថ្នាក់ អ្នកសង្កេតការណ៍សង្គមស៊ីវិល និងអ្នកសង្កេតការណ៍គណបក្ស ដើម្បីអោយដឹងឮទាំងអស់គ្នា ដើម្បីកុំអោយទៅបកស្រាយថាកន្លែងនេះខ្ញុំមិនបានឮ កន្លែងនេះខ្ញុំមិនបានដឹង ចំនុចនេះជាការសំខាន់ណាស់។ ដូច្នេះខ្ញុំបាទសូមអនុញ្ញាតិអោយ លោកស្រីអៀង សូភី និងលោកស្នងការ មេត្តាឆ្លើយនូវចំនុចដូចតទៅ

របស់លោកពិសិទ្ធ ទី១ បញ្ហាការចុះឈ្មោះ ទី២ រឿងអត្តសញ្ញាណប័ណ្ណ និងសៀវភៅគ្រួសារ។

របស់លោក វិរស់ បញ្ហាទាក់ទងទៅនឹងប័ណ្ណព័តិមានផ្តល់បណ្តើរអោយកែឈ្មោះបណ្តើរ។

របស់លោក សារ៉ាត លើកថាសូមអោយកម្មវិធីប្រជុំសប្តាហ៍នេះអោយមានលក្ខណៈជាទៀងទាត់។

របស់លោក ចាន់ ដា បញ្ហារឿងចុះឈ្មោះបោះឆ្នោត ដោយលើកថាមានចល័តច្រើន គ្រួសារអ្នករកស៊ី។

ហើយទាក់ទងបញ្ហាសន្តិសុខជូនទៅលោកស្នងការ

បញ្ហាទាក់ទងទៅនឹងការិយាល័យបោះឆ្នោតដែលបង្កើនចំនួនពី៤២ទៅ៥៣ ក៏នៅតែមានការពិបាកដល់អ្នកបោះឆ្នោតនៅឆ្ងាយៗពីកន្លែង។

ចំពោះលោក ហ៊ុយ ម៉ាំង គាត់មានបញ្ហាពីការចុះឈ្មោះបោះឆ្នោតដែរ។ លោកសូមអោយពិចារណាថា ហេតុអីចុះឈ្មោះច្រើនដល់បោះឆ្នោតទៅតិច តើហេតុផលនោះយ៉ាងម៉េច ?

ហើយបញ្ហាដែលថា តើនៅក្នុងបទបញ្ញាទីតិវិធីរបស់ គជប តើមានការដាក់ទោសបញ្ញាតិ ឬទេ ?

របស់លោក ណាង ជាពិសេសទាក់ទងទៅនឹងបញ្ហាអត្តសញ្ញាណប័ណ្ណ ក្នុងការដែលខុសអក្ខរាវិរុទ្ធ ឬក៏ខូចធ្វើថ្មីឡើងវិញប៉ូលីសដែលអ្នកទៅធ្វើនោះទារ៥ម៉ឺនរៀល សូមបញ្ជាក់ថា ហេតុអ្វី ?

**លោកស្រី អៀង សូភី** ក្រោយពីទទួលស្ដាប់ការបញ្ចេញយោលបល់ ខ្ញុំយល់ថាការយល់ដឹងក្នុងការបោះឆ្នោតនៅក្រុងប៉ៃលិនយើងមានការរីកចំរើនច្រើន នេះជាមោទនភាពមួយរបស់ខ្ញុំដែរ។ តាមការសរុបរបស់លោក ឌិក សេរី សោភក្ដិ មានសំនួរ៥ដែលខ្ញុំត្រូវឆ្លើយជូន។ ឆ្លើយតបទៅលោក ប៊ុន គីមសេង ដែលជាសមាជិករងក្រុមប្រឹក្សាសង្កាត់បយ៉ាខា អំពីការចុះឈ្មោះ។ ក្នុងបញ្ហាអាសយដ្ឋាននេះយើងមានចែងហើយថា អ្នកហ្នឹងមានទីលំនៅពិតប្រាកដបានយើងចុះឈ្មោះអោយ ខ្ញុំសូមត្រឡប់ទៅមើលនីតិវិធី និងច្បាប់ដែលបានចែង ដូច្នេះយើងដូចជាបានបញ្ជាក់ជូនច្បាស់លាស់ហើយថាបើ គាត់មិនមានទីលំនៅពិតប្រាកដទេ យើងមិនអាចចុះជូនគាត់បានទេ ហើយយើងក៏បានជជែកគ្នាច្រើនណាស់ ថាតើអ្នកហ្នឹងមានទីលំនៅពិតប្រាកដនេះមកនៅប៉ុន្មានខែឡើងទៅ ? រឿងនេះលោកខាងក្រុមប្រឹក្សាទិមួយៗបានដឹងហើយ នេះពីព្រោះ គជប បានធ្វើប្រតិភូកម្មអំណាចជូនទៅខាងក្រុមប្រឹក្សាហើយ ព្រោះកន្លងមកយើងមានការគិតឃើញអញ្ចឹង ព្រោះថាបើគណៈកម្មាធិការធ្វើគណៈកម្មាធិការក្ដាប់អត់បានទេមិនដឹងប្រជាពលរដ្ឋចេញចូលយ៉ាងម៉េច អញ្ចឹងខ្ញុំថាបញ្ហានេះខ្ញុំបានបញ្ជាក់ជូនច្បាស់លាស់អស់ហើយ។

ហើយចំពោះការបារម្ភរឿងដែលអត់មានអត្តសញ្ញាណប័ណ្ណយើងក៏បានបញ្ជាក់ជូនហើយថា គជប នឹងចេញជូននូវទំរង់១០-១៨ ហើយយើងបាននិយាយគ្នាហើយកន្លងមកគឺថាសូមរូបថត២សន្លឹកភ្ជាប់មកជាមួយ ដើម្បីអោយ១០-១៨នេះមានសុពលភាពពិតប្រាកដ បើអត់រូបថតយើងអត់ធានាថា មុខអ្នកណា ឈ្មោះអ្នកហ្នឹងទេ ហេតុអីបានជាគេចេះតែទាមទារថាឯកសារបញ្ជាក់អត្តសញ្ញាណ ការបញ្ជាក់សញ្ជាតិ វាមានហើយតែការបញ្ជាក់អត្តសញ្ញាណថា តើមុខហ្នឹង ឈ្មោះហ្នឹងពិតប្រាកដឬអត់យើងត្រូវការមានរូបថត អញ្ចឹងហើយបានទាមទារសៀវភៅគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ ឬប័ណ្ណមន្ត្រីរាជការដែលមានបិទរូបថតនៅលើហ្នឹង។ ឧទាហរណ៍ដូចនៅខាងលោក ប៉ូលីស បើគាត់កាន់ក្រដាសមួយសន្លឹកទៅបោះលើកក្រោយគាត់យក ១០-១៨ទៅទៀត អ្នកផ្សេងទៀតយកមកមួយទៀតព្រោះខ្ញុំបានជួបប្រទះហើយគឺឃើញមក២ដង អញ្ចឹងបញ្ហានេះយើងត្រូវមានអីបញ្ជាក់អត្តសញ្ញាណអោយច្បាស់ហើយក្នុងកិច្ចដំណើរការពេលដែលដំណើរការយើងតែងតែបានជួបប្រទះបញ្ហាភ្លែកៗក៏យើងចេះតែខំដកបទពិសោធន៍អញ្ចឹងទៅ ហើយខ្ញុំឃើញប្រជាជនមួយចំនួនមានការពិបាកខ្លះដែរ រឿងបញ្ហារូបថត ប៉ុន្តែខ្ញុំក៏សូមចិត្តថាប្រហែលជាត្រូវចំណាយ៤០០០រៀលដើម្បីថតបានហ្វីលមួយទុកប្រើប្រាស់ទៀត ហើយខ្ញុំក៏សូមអង្វរគាត់តាំងពីខែមករាហើយថាបើយើងគិតជាសេដ្ឋកិច្ចប្រជាពលរដ្ឋជួយសន្សំមួយថ្ងៃ១០០រៀលទៅដល់ថ្ងៃហ្នឹងយើងបានហើយបាន៤០០០រៀលដើម្បីថតរូប ខ្ញុំដឹងថាមានការលំបាក តែបើយើងគិតយើងមានចេតនាចង់ចូលរួមខ្ញុំឃើញថាយើងអាចធ្វើទៅបាន។

ហើយអំពីបញ្ហាមួយទៀតគឺថា ហេតុអីចុះឈ្មោះច្រើនដល់បោះឆ្នោតទៅតិច ? ខ្ញុំសូមជម្រាបជូនមិនដឹងលោក ហ៊ុយ ម៉ាំង បាននៅក្នុងព្រឹត្តិការណ៍នោះឬអត់ទេ នៅក្នុងឆ្នាំ២០០២ដែលយើងចុះឈ្មោះហ្នឹង ប្រទេសថៃបានបិទព្រំដែនមួយរយៈមិនអោយប្រជា

ពលរដ្ឋចេញទៅរកស៊ីនៅស្រុកថៃ ពេលនោះប្រជាពលរដ្ឋខ្មែរនៅស្រុកថៃទាំងប៉ុន្មានត្រូវបញ្ជូនមកស្រុកខ្មែរវិញទាំងអស់ ហើយជាតំណាក់កាលចំពេលដែលយើងចុះឈ្មោះ ហើយដល់ពេលចុះឈ្មោះហើយ ដល់ពេលបោះគាត់ត្រូវត្រឡប់ទៅរកស៊ីនៅស្រុកថៃវិញព្រោះគេបើកព្រំដែនវិញហើយ ដូច្នេះបើនិយាយពីការគំរាមកំហែង ខ្ញុំសូមធានាថាអត់មានទេបញ្ហាហ្នឹង ព្រោះក្រពះរបស់គាត់ គាត់ត្រូវការទៅរកស៊ីហើយច្បាប់ស្រុកគេយើងមិនអាចទៅមក១យើងធ្វើបាននៅក្នុងក្របខ័ណ្ឌស្រុកយើងនៅឡើយទេ យើងមិនអាចទាក់ទងយើងមានថាអីឡូវអោយគាត់មកបោះបាន ប៉ុន្តែថាអោយមានលក្ខណៈពិសេសសំរាប់អ្នករកស៊ីនោះទៅបោះមុនដូចប្រទេសថៃអីមិនទាន់រៀបចំកើតទេរឿងហ្នឹង មានថ្ងៃតែមួយបោះទូទាំងប្រទេសតែម្តង។ ខ្ញុំសូមឆ្លើយភ្ជាប់ជាមួយតែម្តងទៅបញ្ហាទោសបញ្ញត្តិមានចែងហើយខ្ញុំចាំមិនបានប្រាកដទេមិនដឹងជំពូកទី១៥-១៦យើងចែងអស់ហើយ ហើយឆ្នាំ២០០៣ដែលយើងបានបោះឆ្នោតក៏ គជប បានដាក់ពិន័យទៅលើប្រធានភូមិអ្នកដែលបានប្រព្រឹត្តិល្មើសមួយចំនួនដែលដកហូតសិទ្ធបោះឆ្នោតនិងផាកពិន័យនៅតាមខេត្តមួយចំនួនដែរនេះយើងបានចែងមកហើយ។

ទី២ទៅលើការចែកប័ណ្ណខ្ញុំសូមអរគុណលោកខ្ញុកដែលគាត់ថា គាត់បានព្យាយាមទទួលហើយរឿងនេះថាកែ កែហើយយើងកែតំរូវ ខ្ញុំថានៅលើគល់ប័ណ្ណសង្កាត់រងទាំងអស់ដែលធ្វើដឹងហើយ យើងបានកែជូនហើយនៅលើគល់ប័ណ្ណ ពេលដែលចែកទៅឃើញខុសយើងកែនៅលើគល់ប័ណ្ណជូនគាត់រួចហើយ។ បញ្ហានេះហើយដែលធ្វើអោយដំណើរការចែកប័ណ្ណយើងមិនសូវបានលឿន ពិព្រោះការកែតំរូវច្រើន ជួនកាលរកមនុស្សមិនឃើញទៅទៀត ហើយគណបក្សយើងក៏បានទទួចដែរ ថាស្គាល់ប៉ុន្មានជួយហែកយកទៅចែកទៅអោយតែស្គាល់ពិតប្រាកដហើយយើងមកបញ្ជាក់ជាមួយក្រុមប្រឹក្សាបាន ប៉ុន្តែវានៅត្រង់ថាឈ្មោះជួនកាលវាអត់ច្បាស់ទៅទៀតបញ្ហានេះយើងទទួលស្គាល់ទាំងអស់គ្នាថាយើងមានការលំបាកតែយើងអត់រាថយទេ យើងប្រឹងប្រែងខំធ្វើបន្តទៅទៀត។

ហើយចំពោះបញ្ហាការិយាល័យ។ ខ្ញុំឃើញថាការបង្កើតការិយាល័យចល័តនេះ ខ្ញុំឃើញថាជាគំនិតល្អ ហើយខ្ញុំក៏សូមកោតសរសើរលោក ឈុន ចាន់ដា ដែលបានព្យាយាមរកអនុសាសន៍ល្អ១ច្រើន ប៉ុន្តែខ្ញុំថាបញ្ហានេះវាទាក់ទងនឹងបញ្ហាជាច្រើនដើម្បីរៀបចំការិយាល័យចល័តមួយបាន។ ទី១ យើងសួរថា តើគណបក្សគេទុកចិត្តឬអត់ ក្នុងការលើកហឹបពីកន្លែងមួយទៅកន្លែងមួយ គ្រាន់តែបោះមួយកន្លែងហើយដឹកមករាប់មួយកន្លែងនៅមានបញ្ហាមន្ទិលសង្ស័យគ្នា អនុសាសន៍នេះជាគំនិតល្អ ប៉ុន្តែតើដំណើរការរៀបចំយ៉ាងម៉េច ? ខ្ញុំគិតថា គជប ប្រហែលជាខិតខំប្រឹងប្រែងរិះរក ខ្លួនខ្ញុំផ្ទាល់ក៏ខិតខំដែរថា តើយើងចេញទៅផ្លូវណា ខ្ញុំឃើញថាគំនិតនេះល្អបើយើងធ្វើបាន ប៉ុន្តែសួរថាត្រង់ថាធ្វើបានឬមិនបាន ដូចខ្ញុំជម្រាបពីមុននេះវាមាននៅកត្តាពាក់ព័ន្ធជាច្រើនដែលយើងត្រូវសិក្សាសិនវាពាក់ព័ន្ធថវិការ វាពាក់ព័ន្ធនឹងការព្យាយាមរបស់បុគ្គលដែលធ្វើការ វាពាក់ព័ន្ធនឹងគណបក្សថា តើសំលេងទាំងអស់គ្នាគិតឃើញយ៉ាងម៉េចសិន នេះគ្រាន់តែជាគំនិតមួយល្អដែលយើងគួរយកទៅពិចារណា។

ចុងក្រោយគឺបញ្ហាការប្រជុំ។ ខ្ញុំចង់ជម្រាបថាការប្រជុំនេះ ខ្ញុំបានធ្វើនៅពេលណាដែលគណៈកម្មាធិការបានតែងតាំង ពិព្រោះក្នុងឋានៈជាអាជ្ញាធរបោះឆ្នោតយើងមានកាត្តាបកិច្ចនិងសិទ្ធអំណាចធ្វើពេញដៃ នៅពេលដែលគណៈកម្មាការពេញរូបពេញរាង អញ្ចឹងក្នុងពេលនេះដែលគេហៅថា ពេលបន្តនិរន្តរភាពនេះ ខ្ញុំមិនមានធ្វើការប្រជុំទេ លើកលែងតែការងារចាំបាច់ដូចជាការចែកប័ណ្ណ ឬមានករណីអីចាំបាច់ខ្ញុំអញ្ជើញមកផ្សព្វផ្សាយទាំងអស់គ្នា ក៏ប៉ុន្តែបើថាអត់ទេ ខ្ញុំអត់មានប្រជុំប្រចាំសប្តាហ៍ទេ លុះត្រាតែពេលណាគណៈកម្មាការខេត្តក្រុងត្រូវបានតែងតាំង ពេលនោះលោកស្នងការដឹងហើយ លោកខាងរាជអាវុធហត្ថក៏ដឹងដែរ ថាការប្រជុំសប្តាហ៍នេះនឹងចាប់ផ្តើមដំណើរការជារៀងរាល់អាទិត្យ។ ហើយខ្ញុំសង្ឃឹមថា ការបោះឆ្នោតខាងមុខនេះយើងនឹងខិតខំធ្វើយ៉ាងណាអោយចេញជាលទ្ធផលពិតប្រាកដថែមទៀត ដោយយកការទំនាស់គ្នាមកដាក់លើតុ ជជែកគ្នារកដំណោះស្រាយ។

**លោក ឱក សេរី សោភក្តិ៍** ខ្ញុំបាទសូមអរគុណនូវចំលើយរបស់លោកស្រី អឿងសូភី ដែលជាប្រធានលេខាធិការដ្ឋាននៅក្រុងប៉ៃលិនបានឆ្លើយដោយច្បាស់ៗនិងស្មោះត្រង់ ហើយអ្វីដែលនៅសល់ការដែលត្រូវជជែកគ្នាទៀតគឺអាចនឹងជជែកគ្នាទៀតនៅពេលដែលមានប្រជុំប្រចាំសប្តាហ៍។ ហើយនៅបញ្ហា២ទៀតខ្ញុំបាទសូមអនុញ្ញាតិជូនទៅលោកស្នងការ បញ្ហារឿងសៀវភៅគ្រួសារយក១០០បាត ហើយបញ្ហាអត្តសញ្ញាណប័ណ្ណអក្ខរាវិរុទ្ធខុស ឬមួយធ្វើឡើងវិញ ឬធ្វើម្តងទៀតយកប្រាក់៥ម៉ឺនរៀល។

**លោក ផា ធា ស្នងការរងទទួលបន្ទុកសន្តិសុខក្រុងប៉ៃលីន** ខ្ញុំបានធ្វើការងារនេះច្រើនណាស់ទាក់ទងការងារសន្តិសុខរៀបចំការងារបោះឆ្នោត។ ខ្ញុំសូមបំភ្លឺជូនពាក់ព័ន្ធសៀវភៅគ្រួសារនិងអត្តសញ្ញាណប័ណ្ណ ក្នុងនេះវាមានភាពខុសប្លែកពីគ្នា ការផ្តល់អត្តសញ្ញាណប័ណ្ណនិងសៀវភៅគ្រួសារវាមានជំហានខុសៗគ្នា មុននឹងយើងធ្វើសៀវភៅគ្រួសារទាល់តែយើងមានបញ្ជីក១ និងក៨ កាលណាអត់មានបញ្ជីក១ និងក៨ យើងមិនអាចផ្តល់អត្តសញ្ញាណប័ណ្ណបាន ឬក៏សៀវភៅគ្រួសារបាន។ ចំពោះបញ្ជីក១ និងក៨ យើងសំដៅអ្នកស្នាក់នៅពិតប្រាកដ ឬបណ្តោះអាសន្ន ឧទាហរណ៍ ជួនកាលគាត់ផ្ទេរពីបាត់ដំបង់មករស់នៅក្រុងប៉ៃលីន ពេលនោះពលរដ្ឋបាលខាងបាត់ដំបងអត់មានចុះហត្ថលេខាអោយគាត់ផ្ទេរមកនៅក្រុងប៉ៃលីនទេ ឬគាត់សូមធ្វើនៅប៉ៃលីនប៉ុន្តែអត់មានការផ្ទេរខេត្តបាត់ដំបង យើងមិនអាចផ្តល់អោយបានតាមជំនាញ។ ចំពោះក៨ គឺការស្នាក់នៅពិតប្រាកដយើងផ្តល់បានលុះត្រាតែមានមូលហេតុ២ ។ មូលហេតុទី១គឺទាល់តែអាជ្ញាធរភូមិចៅសង្កាត់ទទួលស្គាល់ជាផ្លូវការ ទី២ មានការអះអាងពីសាក្សីជុំវិញលំនៅដ្ឋាន ទី៣ ទើបយើងផ្តល់ជូនជាស្ថាពរ។ ចំពោះអត្តសញ្ញាណប័ណ្ណគឺការផ្តល់ជូននៅក្រុងប៉ៃលីនរបស់យើងមកដល់ថ្ងៃនេះគឺបានដល់ប្រជាពលរដ្ឋដែលមានសិទ្ធបានអត្តសញ្ញាណប័ណ្ណគឺបានតែ៦៥ភាគរយ ចំពោះមូលហេតុដែលយើងផ្តល់យឺតនេះគឺ ដោយសាររដ្ឋអំណាចមូលដ្ឋានគាត់មិនសូវចូលរួមសហការណ៍ក្នុងការប្រមូលផ្តុំប្រជាពលរដ្ឋ ដើម្បីអោយក្រុមការងារយើងខ្ញុំចុះទៅបំពេញការងារអោយបានចប់ចុងចប់ដើម ឧទាហរណ៍ដូចជាសង្កាត់អូតាវៅមួយ មានថ្ងៃខ្លះយើងផ្តល់បាន២៥នាក់ មានថ្ងៃខ្លះបាន៣០នាក់ ហើយយើងគិតប្រជាជនដែលផ្តល់អត្តសញ្ញាណប័ណ្ណក្នុងសង្កាត់អូតាវៅមួយមានច្រើន គាត់លើកមូលហេតុថាជាប់រវល់ធ្វើចំការ មកទល់ថ្ងៃនេះគឺគោលការណ៍ថ្នាក់លើបានបិទឈប់ផ្តល់អត្តសញ្ញាណប័ណ្ណនៅខែធ្នូឆ្នាំ២០០៦ដើម្បីរៀបចំការងារបោះឆ្នោត។ បោះឆ្នោតលើកនេះដើម្បីបំរើអោយការបោះឆ្នោតទាល់តែយើងមានសៀវភៅគ្រួសារនិងអត្តសញ្ញាណប័ណ្ណ គឺយើងឈប់ប្រើផ្លាកសញ្ញា គជប អញ្ចឹងវាមានមូលហេតុរបស់វា ចំពោះលោកសេង ចៅសង្កាត់បយ៉ាខាន់លើកពីការផ្តល់សៀវភៅគ្រួសារនោះគឺវាមានមូលហេតុចំពោះសង្កាត់បយ៉ាខាន់ ទី១ ទាក់ទងនឹងដីការស្វែងចាប់ខ្លួនរបស់តុលាការ ទី២ គឺមុខសញ្ញាសង្ស័យរបស់សមត្ថកិច្ចយើងមិនអាចផ្តល់បាន។ ចំពោះការធ្វើអត្តសញ្ញាណប័ណ្ណនេះយើងមិនអាចធ្វើការផលិតនៅក្រុងប៉ៃលិនបានទេ ជាក្រុមហ៊ុនផលិតនៅភ្នំពេញ អញ្ចឹងគឺថាកំព្យូទ័រដែល ឧបមាក្នុងមួយខែយើងធ្វើបាន១០០០នាក់ គឺយើងយកកំព្យូទ័រនោះទៅភ្នំពេញទៅបូមយករូបបញ្ចូលក្នុងក្រុមហ៊ុនគេផលិតនៅក្រុមហ៊ុនតែម្តង យើងមិនបានធ្វើនៅក្រុងប៉ៃលីនទេ ហើយការបាត់អត្តសញ្ញាណប័ណ្ណគឺជាការទទួលខុសត្រូវរបស់បុគ្គល ព្រោះថាការបាត់អត្តសញ្ញាណប័ណ្ណចំពោះម្នាក់ យើងគិតថាប្រហែលជា២-៣ខែតែម្នាក់ទេដែលបាត់អត្តសញ្ញាណប័ណ្ណមួយ ដែលគ្នាយកលុយនោះគឺជិះឡានទៅបូមយកពីភ្នំពេញមកវិញ នេះដែលយើងយកទៅ យើងមិនអាចផលិតនៅក្រុងប៉ៃលីនបានទេ គឺផលិតនៅក្នុងក្រសួងមហាផ្ទៃ អញ្ចឹង៥០០បាតនោះគឺគ្នាយកសាហ៊ុយទៅបូមយករូបនោះមកវិញដើម្បីអោយក្រុមហ៊ុនផលិតជាថ្មី ហើយបើយើងគិត៥០០បាតទៅមិនដល់ទេ១០០០បាត អញ្ចឹងយើងគិតថាក្នុង៣ខែមានមនុស្សតែម្នាក់ទេដែលបាត់ នេះមិនមែននិយាយចេះតែយកវិធីដោះស្រាយនោះទេ ខ្ញុំគិតថាមួយឆ្នាំមានតែមួយទេ។ ហើយកន្លងមកនេះឯកឧត្តមជាឈឿន ក៏គាត់បាត់អត្តសញ្ញាណប័ណ្ណ អញ្ចឹងគាត់ថាត្រូវធ្វើយ៉ាងម៉េច ថាត្រូវតែអោយប៉ូលីស១០០០បាតគាត់ថាយកទៅធ្វើអី ? ជិះឡានទៅ ទៅបូមយកពីភ្នំពេញមកវិញផលិតថ្មី ព្រោះឯកសារគេនៅភ្នំពេញគេអត់អោយស្នងការយើងគ្រប់គ្រងទេ គេអោយក្រុមការងារនៅក្រសួងមហាផ្ទៃជាអ្នកគ្រប់គ្រង នាយកដ្ឋានអត្តសញ្ញាណប័ណ្ណ អញ្ចឹងយើងទៅបូមយកមកវិញ

ហើយផលិតថ្មីយកមកអោយវិញ ដល់អញ្ចឹងគាត់អោយ២០០០បាតអោយលើសតែម្តង។ គាត់គិតថាឡានទៅមកពីរយប់ពីរថ្ងៃទៅភ្នំពេញ យើងមិនអាចផលិតនៅក្រុងប៉ៃលិនបានទេ នេះចំពោះហេតុផល។

ហើយចំពោះការងារទាក់ទងនឹងវិស័យសន្តិសុខក្នុងការការពារបោះឆ្នោត ខ្ញុំឃើញថាចំនុចខ្វះខាតរបស់ប៉ូលីស របស់កងរាជអាវុធហត្ថដែលបានចូលរួមសហការណ៍គ្នាក្នុងការការពារការបោះឆ្នោតនេះ មានការចន្លោះរបស់សមត្ថកិច្ច ប៉ុន្តែខ្ញុំគិតថានេះជាកិច្ចការមួយបន្តិចបន្តួច ខ្ញុំលើកឧទាហរណ៍ការបោះឆ្នោតនៅភ្នំព្រាល ក៏មានចន្លោះ នេះបើផ្អែកទៅលើភូមិសាស្ត្រ បើយើងគិតក្នុង៥០ម៉ែត្រនោះជុំវិញនោះសិតតែទឹក អោយប៉ូលីសទៅឈរក្នុងទឹកដូចម្តេចកើត យើងត្រូវតែប្រខិតមក៤០ម៉ែត្រ វាផុតទឹកលើខ្នងទំនប់ ហើយពេលនោះមានភ្លៀងផង អោយគ្នាទៅឈរក្នុងទឹក ឬហាលភ្លៀង ដូច្នេះសូមធ្វើការខិតចូលមានគណបក្សនិងអង្គការមួយចំនួនធ្វើការចោទប្រកាន់ ប៉ុន្តែប៉ូលីសហ្នឹងមិនបានទៅធ្វើការគំរាមកំហែងប្រជាពលរដ្ឋទេ ពេលនោះខ្ញុំនៅទីបញ្ជាការការនៅប្រចាំតំបន់ភ្នំព្រាលដើម្បីការពារសន្តិសុខនៅទីនោះខ្ញុំមានកងកំលាំងខ្ញុំប្រហែល២០០នាក់ នៅពន្រាយជុំវិញមណ្ឌលបោះឆ្នោតនោះ រហូតដល់ក្រុមការងារបោះឆ្នោតទាំងយប់ ខ្ញុំប្រើកំលាំងខុសពេលវេលាដែរ គឺថាពេលយប់យើងមិនអាចបញ្ចេញកំលាំងទៅការពារការិយាល័យមានប្រតិកម្មអីផ្សេងៗបានទេ ដោយសារមូលហេតុផ្សេងៗ ក្រុមការងារបោះឆ្នោតសំណូមពរ គឺខ្ញុំចេញ ប៉ុន្តែពេលយប់យើងត្រូវតែប្រើប្រាស់អាវុធ ហើយបើយើងមើលហឹបឆ្នោតហ្នឹងមិនបានសុវិត្ថភាពវាមានបញ្ហាដែរ។

ចំនុចចុងក្រោយជាអនុសាសន៍របស់ខ្ញុំដែលឃើញកន្លងមកនេះ មានលោកខ្លះនិយាយពីការធ្លាក់ផ្លាក់គណបក្សនយោបាយ អញ្ចឹងសូមសំណូមពរគ្រប់គណបក្សនយោបាយទាំងអស់មេត្តាដាក់ផ្លាក់វ៉ែដែកគោលអោយបានមាំ កុំយកទៅចងដាក់បង្គោលឬស្សី ដល់ពេលធ្លាក់ផ្លាក់ចោទថាមានគេរុះរើរ ការពិតខ្យល់ធ្លាក់ខ្លួនឯង នេះខ្ញុំតាមដានដឹងហើយនៅភូមិទូលចង្រិត នៅទួលល្វា សូមអោយដាក់ដែកគោលអោយបានមាំ ឬមានលទ្ធភាពអាចផ្សាដែក។

សូមអោយគណបក្សនយោបាយទាំងអស់ចេះយោគយល់គ្នា សង្ឃឹមមកលើសមត្ថិកិច្ច ព្រោះថាសមត្ថិកិច្ចមិនដឹងរឿងច្រើននៅក្នុងការបោះឆ្នោតទេ គឺសមត្ថកិច្ចនៅឆ្ងាយណាស់ពីការងារបោះឆ្នោត គ្រាន់តែមានការរៀបចំសណ្តាប់ធ្នាប់តែប៉ុណ្ណោះ។ ហើយសូមកុំអោយបង្កើតសន្តិសុខឯកជន ករណីនេះបើមានគឺសមត្ថកិច្ចត្រូវតែបង្ក្រាប តែកាល ណាបង្ក្រាបគឺមានការប៉ះពាល់ព្រោះសន្តិសុខនេះជាសន្តិសុខអនាធិតេយ្យក្នុងច្បាប់បោះឆ្នោតអត់មានច្បាប់បង្កើតសន្តិសុខទេ បើបង្កើតសន្តិសុខ ប៉ូលីសឯណាដែលអាចចូលរួមការពារសន្តិសុខបាន សំណូមពររបស់ខ្ញុំជាអនុសាសន៍មួយដែរ ព្រោះកន្លងមកខ្ញុំធ្លាប់ធ្វើការជួបបញ្ហានេះ ដូច្នេះហើយបានជាខ្ញុំលើក។ ប៉ុន្តែជាចុងក្រោយសំណូមពរដល់ចៅសង្កាត់ មេភូមិគ្រប់ទាំងអស់ ព្រោះថារយៈពេលនៃការធ្វើអត្តសញ្ញាណប័ណ្ណនេះ សមត្ថិកិច្ចយើងខ្ញុំនឹងបង្កើតក្រុមការងារ ហើយខ្ញុំនឹងទៅតឿនថ្នាក់លើដើម្បីយកម៉ាស៊ីនកំព្យូទ័រថ្មីមកទៀត ព្រោះរយៈពេលយើងនៅខ្លីណាស់ បើសិនជាអាចប្រមូលប្រជាពលរដ្ឋមិនអោយធ្វើចំការមួយថ្ងៃ ដូចជាសង្កាត់បយ៉ាខា លោកសេង បើសិនមានលទ្ធភាពសូមប្រមូលប្រជាពលរដ្ឋដែលមានអាយុចាប់ធ្វើអត្តសញ្ញាណប័ណ្ណបាន សូមប្រមូលគាត់មកនៅជុំគ្នា ខ្ញុំនឹងបញ្ជូនក្រុមការងារខ្ញុំទៅផលិតនៅកន្លែងនោះភ្លាម ព្រោះនៅរយៈពេលតែប៉ុន្មានខែទៀតទេ នេះជាសំណូមពរដ៏ទទូចរបស់សមត្ថិកិច្ចយើងខ្ញុំ ក៏ដូចជាក្រសួងមហាផ្ទៃ។

ហើយទាក់ទងការធ្វើសៀវភៅគ្រួសារនេះដែរ សៀវភៅគ្រួសារនេះលោកត្រូវតែជំរុញ ព្រោះថាលោកមានសិទ្ធហើយចៅសង្កាត់លោកត្រូវតែជំរុញប៉ុស្តិ៍រដ្ឋបាល ព្រោះប៉ុស្តិ៍រដ្ឋបាលជាជំនួយការអោយក្រុមប្រឹក្សាឃុំសង្កាត់នោះឯង ត្រូវតែជំរុញដើម្បីធ្វើបញ្ជី ក១ និង ក៨ អោយបាន។ ខ្ញុំសូមសំណូមពរអោយមេភូមិចៅសង្កាត់ទាំងអស់ចូលរួមសហការណ៍ជាមួយក្រុមការងារធ្វើអត្តសញ្ញាណប័ណ្ណហ្នឹងអោយបានសម្រេចនៅរយៈពេលដ៏ខ្លីនេះ។

**លោក ឱក សេរី សោភ័ក្តិ** ខ្ញុំបាទសូមជូនសំដីទៅខាងបងស្រី ព្រោះមិនទាន់មានប្រសាសន៍សោះ។

**លោកស្រី ប៉ែន ដារ៉ា គណបក្ស សម រង្ស៊ី ក្រុងប៉ៃលិន** ខ្ញុំសូមនិយាយអោយចំចំនុចគឺថា នៅសភាពការណ៍ក្រុងប៉ៃលិននេះ តាំងពីមុនមក តាំងពីយើងបោះឆ្នោត៣អាណត្តិហើយ គឺថាអាណត្តិទី១ នៅក្រុងប៉ៃលិននេះសភាពការណ៍តឹងតែងមែនទែន សភាពការណ៍នៅឆ្នាំ៩៨បោះឆ្នោតហើយមានបាញ់គ្នា តែមកដំណាក់កាលទី២ បោះឆ្នោតឆ្នាំ២០០០មេឃុំ ដាក់ផ្លាក់ពីល្ងាចព្រលឹមឡើងធ្លាក់អស់នេះខាងលោកស្នងការគាត់មិនទទួលការពិតទេថាផ្លាក់នោះធ្លាក់ដោយសារខ្យល់ព្យុះនោះក៏វាមិនអីដែរ វាហួសពេលនិយាយហើយ មកដល់ដំណាក់កាលនេះហើយគឺសភាពការណ៍វាធូរស្រាលហើយ ។ វាមិនដែលផ្លាក់ណាហើរទៅក្នុងទឹកត្រពាំងដ៏ជ្រៅហើយលើកដុំថ្មសង្កត់ទៀតទេ វាមិនដែល យើងនិយាយអោយវាយុត្តិធម៌។ ហើយការចាប់សកម្មជនយកទៅដាក់ខ្មោះ វាខុសលោកស្នងការក៏អត់មានទទួលស្គាល់ការពិតដែរ តែវាមកដល់ដំណាក់កាលនេះហើយខាងគណបក្សខ្ញុំក៏លើកលែងទោសដោយសារតែការយោគយោលគ្នា ដោយសារលទ្ធិប្រជាធិតេយ្យមានដំណើរការទៅមុខបន្តិចម្តងៗ ហើយដូចលោកស្រីប្រធានគាត់ថានយោបាយវាកាន់តែចាស់ទុំបន្តិចម្តងៗខ្ញុំក៏ទទួលស្គាល់ការពិត នៅក្រុងប៉ៃលិននេះគឺថាសភាពការណ៍ទី១ ទី២ នេះគឺតឹងតែងមែនទែនករណីគំរាមកំហែងដាក់ខ្មោះ គឺឃើញអស់ហើយខាងគណបក្សសម រង្ស៊ី ខ្ញុំតាំងចិត្តថាអ្វីដែលខំព្យាយាមធ្វើដែលខំតស៊ូដើម្បីលទ្ធិប្រជាធិតេយ្យនេះ ថាធ្វើអោយដល់ទិសដៅទោះបីលំបាកយ៉ាងណាក៏ត្រូវតែខិតខំត្រូវតែព្យាយាម។ ហើយការបោះឆ្នោតបើតាមការចុះឈ្មោះចំនុចសំខាន់ទាំង៣នេះ វាជួបការលំបាកច្រើនណាស់ គឺថាចុះឈ្មោះហើយត្រូវការអ្នកសង្កេតការណ៍ដែលអាណត្តិលើកមុននេះអ្នកសង្កេតការណ៍គឺថា ពីមុនពួកខ្ញុំមានដែរតែក្រោយៗមកអត់លុយ ដល់អញ្ចឹងអ្នកសង្កេតការណ៍ត្រូវការទារលុយហើយ អញ្ចឹងដល់ទៅក្រុមប្រឹក្សាលើកនេះចេះតែបណ្តោយខ្លះទៅ ពិនិត្យខ្លះទៅ ជឿជាក់លើក្រុមប្រឹក្សាសង្កាត់ដោយសារអស់លោកម្នាក់ៗសិតតែមានឧត្តមគតិហើយ មានការទុកចិត្តគ្នាហើយសភាពការណ៍តឹងតែង ក៏ខ្ញុំសូមថ្លែងអំណរគុណដល់ឯកឧត្តម ម៉ៃ ណាត់ ហើយនិងលោកស្រីប្រធានដែរ គឺថាបញ្ហាខ្លាំងជាងគេ គឺថាសត្រូវស្លាប់រស់ហើយប៉ៃលិននេះបោះឆ្នោត តែបានឯកឧត្តមប្រធាន លោកស្រីប្រធានហៅមកធ្វើការប្រជុំតុមូលញ៉ឹក អញ្ចឹងការដែលទល់មុខគ្នាការជជែកគ្នាពិភាក្សាគ្នាវាបានសភាពធូរស្រាលវិញ វាយល់ពីទឹកចិត្តគ្នា ខ្ញុំប្រាប់ត្រង់កាលពីបោះឆ្នោតមេឃុំហើយ ហៅខ្ញុំទៅហត្ថលេខាលើរបាយការណ៍ខ្ញុំអត់ទៅទេ ឡានមកយកពាដងខ្ញុំមិនទៅទេ នេះខ្ញុំសូមជម្រាបខាងតំណាងអង្គការអោយដឹងដែរ ខឹងដែរដល់ខឹងទៅខឹងមកវាខាតផលប្រយោជន៏ទាំងអស់គ្នា។ តែមកដល់សព្វថ្ងៃនេះករណីដែលថាធូរស្រាលហើយនៅក្នុងការចុះឈ្មោះនិងការចែកបញ្ជីហើយគ្រាន់តែថាសភាពការណ៍ដែលត្រូវចុះឈ្មោះបោះឆ្នោតជិតមកដល់ហើយករណីគំរាមកំហែងចាប់ផ្តើមកើតឡើងទៀតហើយឥឡូវនេះ កើតឡើងនៅសង្កាត់ទួលល្វា គ្រាន់តែដាក់ផ្លាក់ហើយក៏ហៅសកម្មជនខ្ញុំ មេឃុំនៅក្នុងសង្កាត់ទួលល្វាហ្នឹង ហើយហៅក្រុមប្រឹក្សាខ្ញុំថា នៃប្រយ័ត្ននៅជុំៗគ្នាហ្នឹង ប្រយ័ត្ន DSS ទៀតនេះករណីគំរាមកំហែង ហើយករណីខ្ញុំទៅដាក់ផ្លាក់ជូនដំណឹងតាំងពីថ្ងៃទី៥ទៅស្នងការទៀតខ្ញុំដាក់គ្រប់កន្លែងទាំងអស់ ដោយសារអី ? ដោយសារលោកមេឃុំអូតាវៅគាត់ធ្វើការដោយអត់ឯកភាពគ្នា នៅសាលាឃុំគាត់ធ្វើការនៅក្រោមផ្ទះ ដល់ទៅតាមនៅផ្ទះបិទទ្វារហួតគាត់ទៅចំការ ដល់ទៅផ្ទះលោកអួនទៀត គាត់ចេញផុតផ្ញើរទុកនៅប្រពន្ធ ប្រពន្ធគាត់យកទៅអោយលោករុន លោករុនយកទៅអោយលោកស្មៀនទៅដល់ស្មៀនមិនបានអោយលោកមេឃុំដល់ពួកខ្ញុំទៅដាក់ផ្លាក់ មេឃុំគាត់អោយទំលាក់ដកចេញ នេះករណីគំរាមកំហែង តែដោយសារយើងដោះស្រាយយល់គ្នាទៅ។ អញ្ចឹងកិច្ចការសំណូមពរទាំងចុះឈ្មោះ ទាំងសង្កេតការណ៍ ទាំងអីទាំងអស់ដែលមួយដំណើរការបោះឆ្នោតនេះខ្ញុំថា សូមអោយខាងឃុំសង្កាត់ខាងលោកមេភូមិអោយយល់ចិត្តបញ្ហាដាក់ផ្លាក់ ខ្ញុំត្រូវដាក់ផ្លាក់ ខ្ញុំត្រូវចុះរៀបភូមិ អញ្ចឹងបើអោយខ្ញុំចុះទៅភូមិណាអោយខ្ញុំទៅសុំច្បាប់មេភូមិ គឺមិនអាចទេ មិនអាចមេភូមិថា ខ្ញុំត្រូវតែអោយទៅធ្វើចុះបោះឆ្នោតក្នុងភូមិក្នុងអីអញ្ចឹងវាខុសគោលការណ៍គណបក្ស អញ្ចឹងខ្ញុំគ្រាន់តែជូនដំណឹងទេ លើកផ្លាក់ក៏ខ្ញុំគ្រាន់តែជូនដំណឹងដែរ ២៤ខេត្តក្រុងក៏ខ្ញុំគ្រាន់តែជូនដំណឹងដែរ ប៉ុន្តែគាត់អោយទៅធ្វើពីភូមិពីឃុំពីសង្កាត់ដល់ខ័ណ្ឌដល់ក្រុងនេះវាខុសពីគោលការណ៍របស់គណបក្ស អញ្ចឹងសូមជម្រាបដល់អស់លោក

លោកតំណាងមេឃុំទាំងអស់មេត្តាជ្រាបពីថ្ងៃនេះទៅធ្វើម៉េចសូមផ្តល់ឱកាសនៃការលើកផ្លាក់ការកែតំរង់តាមភូមិគឺថា ចាប់ពីស្អែកទៅពួកខ្ញុំចុះបោះឆ្នោតរើសតំណាងក្នុងភូមិ អញ្ចឹងសូមកុំប្រកាន់ទោសពៃអីខ្លាំងពេក ព្រោះអីពេលដែលពួកខ្ញុំធ្វើតែងតែជូនដំណឹងទៅខាងពួកលោកតែពេលពួកលោកធ្វើមិនបានជូនដំណឹងមកខាងពួកខ្ញុំផងទេ។

**លោក ឱក សេរី សោភក្តិ៍** សូមអរគុណដល់បងស្រី មានសេចក្តីក្លាហាន។ រួចហើយខ្ញុំឯកភាពជាមួយលោកអភិបាលខ័ណ្ឌរង គឺនៅទីកន្លែងនេះដូចដែលខេត្តឯទៀត១អញ្ចឹងគឺថា បើសិនមានករណីគំរាមកំហែង ឬក៏រំលោភណាមួយ សូមអោយបានឈ្មោះកន្លែងនោះឈ្មោះភូមិសាស្រ្ត ឈ្មោះអ្នកប្រព្រឹត្តិហើយនិងបញ្ហាករណី ព្រោះគ្មានទីកន្លែងណាដែលមានសុវត្ថិភាពដូចនៅក្នុងយន្តការឧបសែលនេះទេ។

**លោកស្រី កែ ផន ចៅសង្កាត់ក្រុងប៉ៃលិនគណបក្សហ៊្វុនស៊ិនប៉ិច** ខ្ញុំមិនមែនដើរប្រមូលផ្តុំហើយដណ្តើមទាញជាសំលេងគណបក្សនិមួយ១នោះទេ ខ្ញុំឈរជាភាពយុត្តិធម៌ ខ្ញុំទៅបោះទីតាំងនៅកន្លែងណា ក៏ខ្ញុំពន្យល់ប្រជាពលរដ្ឋទាក់ទងនឹងការឈរឈ្មោះដល់ពេលជាសំលេងឆ្នោតពេលដែលខ្ញុំទៅកាន់ភូមិនិមួយ១ខ្ញុំចូលទៅភូមិហ្នឹង ទៅគាត់ក៏ថាគាត់ចូលខាងហ៊្វុនស៊ិនប៉ិច ខ្ញុំមិនដែលមានបញ្ហាទេក្នុងចិត្តដែលប្រជាជនចូលមកជាមួយខ្ញុំទាំងប៉ុន្មានគឺដោយសុទ្ធចិត្តរបស់គាត់មិនដែលមានឮថាមានបញ្ហាទេ តែគ្រាន់ថាសន្លឹកឆ្នោតដែលអស់លោកនិយាយថាចូលមក២០០០ តែចូលទៅសំលេងពិតវាមានតែ១០០០នោះ ដល់ពេលខ្ញុំសួរគាត់ គាត់ថាគាត់មកសំលេងខាងខ្ញុំ តែស្អែកឡើងខ្ញុំឃើញគណបក្សសមរង្ស៊ីទៅគាត់កត់ទៅខាងនោះ ដល់ពេលអញ្ចឹងទៅខ្ញុំក៏ទៅសួរមិនមែនទាញសំលេងទេអស់លោក តែខ្ញុំគ្រាន់តែពន្យល់ថា ចុះបើមីងខ្ញុំកត់អញ្ចើទៅប្រជាជននោះវាជាន់គ្នាហើយ គាត់ថាបងអើយខ្ញុំកត់អោយតែបានស៊ីរង្វាន់ទៅ បានន័យថាប្រជាជនគាត់មិនទាន់យល់ គាត់មិនទាន់ដឹង គាត់វិលដូចក្រសាំងអញ្ចឹង ដល់ខ្ញុំគិតទៅដល់ពេលយើងបោះឆ្នោតនេះស្ថាប័នយើងគ្រប់កន្លែងគឺថាទប់ស្កាត់មិនអោយមានចេញទៅខាងណាមកខាងណីទេ ក៏ប៉ុន្តែដល់ខ្ញុំគិតទៅចំនុចគាត់ខ្វីបំផុតគាត់មិនដឹងថានិស្ស័យយើងទៅជាស្អីទេ។ ខ្ញុំចុះទៅធ្វើនេះមិនមែនអូសទាញបក្សណាជាបក្សណាទេ ខ្ញុំចូលចិត្តណាស់យើងកសាងកំលាំងដែលឈរធ្វើជាតំណាងមួយ១វាត្រូវតែមានហើយ។

ដូចជារឿងអត្តសញ្ញាណប័ណ្ណដែលអស់លោកដែលធ្វើការនៅក្នុងនេះ ខ្ញុំឈរជាភាពយុត្តធម៌យើងមិនអាចទំលាក់ទំងន់មួយ១ដែលជាកំហុសទេ ប៉ុន្តែគាត់អត់យល់ គាត់រស់មក២-៣ជំនាន់ ជំនាន់ដូនតាមករស់ជាគឺថាកាតខ្មៅសំគាល់ខ្លួនឆ្លងកាត់ពីខេត្តមួយទៅខេត្តមួយគាត់មិនដឹងថាគាត់រស់នៅកសាងមានអ្វីដែលជាសេរីភាពរបស់គាត់ផង ដល់ខ្ញុំសួរគាត់ថាបងបានទទួលអត្តសញ្ញាណប័ណ្ណទេ ? គាត់ថាអត់ដល់ខ្ញុំថាអញ្ចឹងអញ្ជើញទៅធ្វើទៅ គាត់ថាអត់ទៅវគ្គទី១ វគ្គទី២ ក៏គាត់មិនទៅ ដល់វគ្គទី៣គាត់ទៅប៉ះគេជាកពិន័យ គាត់ថាគាត់មិនធ្វើទេអត្តសញ្ញាណប័ណ្ណ ដីខ្មែរនៅណាអោយនៅមិនអោយនៅហីទៅគាត់ឆ្លើយដោយខ្ញីអញ្ចឹង។ អញ្ចឹងអស់លោកដែលលើកនៅក្នុងអង្គប្រជុំមិនបាច់លើកថាជាកំហុសអ្នកណាទេ ព្រោះថាខ្មែរយើងនៅមិនទាន់ដឹងថាស្អីជាសំខាន់នៅឡើយផង។ ដូចរឿងអត្តសញ្ញាណប័ណ្ណគេជាកពិន័យគាត់ច្រើនគាត់ដើរជេរគេអញ្ចឹងទៅ ដល់ប្រាប់គាត់អោយធ្វើតាំងពីតិចមកគាត់មិនធ្វើ គាត់ថាគាត់ក្រមិនចាំបាច់ខ្វល់អីទេ។ ខ្ញុំនិយាយនេះគឺត្រង់ហើយអស់លោកទោះបីខ្ញុំខុស ខ្ញុំត្រូវខ្ញុំមិនមានឯកសារព្រាងទុកទេ សណ្តានចិត្តរបស់ខ្ញុំដែលចេញដោយស្មោះ។

**លោក វ៉ៃ សុខុម អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍** ខ្ញុំចាប់អារម្មណ៍ទៅលើប្រព័ន្ធឃោសនានិងមួយទៀតគឺក្រមសីលធម៌។ ក្នុងចំនុចនេះខ្ញុំចង់សួរទៅបងស្រីប្រធានខាងគណៈកម្មាធិការខេត្តរៀបចំការបោះឆ្នោត ពិព្រោះបញ្ហានេះខ្ញុំបានចុះទៅសំរបសំរួលគ្រប់ពេលនៃការឃោសនាបោះឆ្នោត ខ្ញុំចង់សួរថាតើ គជប មានបានបង្កើតនូវក្រមសីលធម៌សំរាប់គណបក្សទាំងអស់ដែលឬទេ ? ពិព្រោះ

ពាក់ព័ន្ធទៅនឹងការឃោសនាដូចបងខាងដើមគាត់និយាយអញ្ចឹង ថាគណបក្សខ្លះមិនគោរពពីគោលការណ៍របស់ខ្លួន។ ហើយចំនុចទី២ ខ្ញុំសួរថាមានង្កើតជាគណៈកម្មាធិការដើម្បីតាមដានឃោសនាហ្នឹងដែរឬទេ ?

**លោកស្រី អៀង សូភី** រឿងបញ្ហាប្រព័ន្ធឃោសនានេះ ចង់និយាយពីយុទ្ធនាការឃោសនាបោះឆ្នោត មែនទែនទៅនៅពេលឃោសនានិមួយៗយើងពឹងផ្អែកទៅលើគណៈកម្មាធិការឃុំសង្កាត់គាត់ជាអ្នកតាមដានពិនិត្យនៅក្នុងរឿងនេះ ហើយគណបក្សនិមួយៗក៏ត្រូវដាក់ពាក្យចូលមកគណៈកម្មាធិការឃុំដែរ គាត់ចង់ធ្វើអី អញ្ចឹងយើងពឹងផ្អែកទៅលើគណៈកម្មាធិការឃុំរៀបចំការបោះឆ្នោតជាអ្នកដំណើរការនេះ។ ហើយចំពោះក្រមសីលធម៌ខ្ញុំសូមជម្រាបថាយើងបានបោះពុម្ពចេញជាសៀវភៅហើយ គឺក្រមសីលធម៌សំរាប់អ្នកសង្កេតការណ៍ក៏មាន សំរាប់គណបក្សក៏មាន សំរាប់មន្ត្រីបោះឆ្នោតក៏មាន ហើយនិងសំរាប់ខាងផ្នែកសន្តិសុខក៏មានដែរ។ ប៉ុន្តែការផ្សព្វផ្សាយខ្ញុំមិនដឹងយ៉ាងណាដែរ ពិព្រោះការចែកចាយនៅមានចំនួនតិចនៅឡើយដែរ។

**លោក ឱក សេរី សោភ័ក្តិ** ដោយសារពេលវេលាមានកំណត់ ខ្ញុំបាទមិនអាចជូនសំដីទៅវាគ្មិនដទៃទៀតទេ ប៉ុន្តែអ្វីដែលវាគ្មិនបានលើកឡើងមួយព្រឹកនេះហាក់ដូចជាជុំវិញនូវបញ្ហាដែលទីក្រុងប៉ៃលិនកំពុងតែជួបប្រទះនៅក្នុងការរៀបចំការបោះឆ្នោតនៅក្នុងឆ្នាំ ២០០៧ហើយនឹងឆ្នាំ២០០៨។ ខ្ញុំសូមជូនសំដីចុងក្រោយនេះទៅលោក ឡារី ស្ត្រេន្ន និងឯកឧត្តមអភិបាលរងលោកមានប្រសាសន៍

**លោក ឡារី ស្ត្រេន្ន** ខ្ញុំបាទសូមអរគុណឯកឧត្តមអភិបាលរង ដែលបានអនុញ្ញាតិអោយខាងខ្ញុំបាទមានយោលបល់ ហើយមែនទែនទៅគឺជាការលំបាកបំផុតសំរាប់ខ្ញុំបាទលើកជាមតិយោបល់ដើម្បីឆ្លើយតបចំពោះមតិរបស់អស់លោកលោកស្រីដែលបានលើកប្រកបទៅដោយបទពិសោធន៍អត្ថន័យខ្លឹមសារជាទីបំផុត។ ដើម្បីឆ្លើយតបទៅលើបញ្ហានេះខ្ញុំបាទសូមលើកចំនុច៣ខ្លីៗ

នៅក្នុងចំនុច១ ដែលខ្ញុំបាទបានព្ញាំងពីតំបូងនៃការពិភាក្សានេះគឺពាក្យថា ចាស់ចិត្ត ចាស់គំនិត នៃតំណាងគណបក្សនយោបាយក៏ដូចជាសង្គមស៊ីវិល ហើយពាក្យនេះគឺជាចំនុចសំខាន់មួយនៃការអភិវឌ្ឍន៏លទ្ធិប្រជាធិតេយ្យ។ តាមរយៈការពិភាក្សាព្រឹកមិញនេះអស់លោកលោកស្រីបានលើកនូវបញ្ហាប្រឈមជាច្រើនដែលមិនទាន់បានដោះស្រាយ ហើយនឹងមិនទាន់កែលំអរអោយបានច្រើន ជាពិសេសគឺជុំវិញការងារបោះឆ្នោតនេះ។ ទន្ទឹមនិងនេះយើងក៏បានលើកពីភាពល្អប្រសើរការរីកចំរើនច្រើនជុំវិញការងារបច្ចេកទេសមួយចំនួន ជាពិសេសពាក់ព័ន្ធនឹងការងារចុះបញ្ជីឈ្មោះបោះឆ្នោត ក៏ដូចជាការចុះអត្តសញ្ញាណប័ណ្ណ ការងាររៀបចំជាបច្ចេកទេសជុំវិញការងារនេះយើងឃើញថា មានភាពរីកចំរើនកាន់តែល្អប្រសើរច្រើន។ នេះជាចំនុចមួយសំខាន់ដែលបញ្ជាក់បង្ហាញអោយកាន់តែច្បាស់ពីការរីកចំរើនធ្វើអោយកាន់តែល្អជាបណ្តើៗ ទាំងការធ្វើអោយរីកចំរើនឡើងនូវបច្ចេកទេសនៃការរៀបចំការបោះឆ្នោត ភាពរីចចំរើននៃវប្បធម៌នៃការពិភាក្សាគ្នានៅក្នុងព្រឹកនេះ។

ចំនុចទី២ ដែលខ្ញុំបាទកត់សំគាល់ដែលនោះគឺ ជុំវិញបញ្ហាតម្លាភាព ហើយនិងការជឿទុកចិត្តគ្នា។ តាមការអង្កេតនៅក្នុងការពិភាក្សានៅក្នុងព្រឹកនេះគឺ ឯកឧត្តមអភិបាលរងក្រុង អ្នកបងខាងប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ខាងលោកស្នងការរង ទាំងអស់លោក លោកស្រីដែលបានលើកឡើងគឺជាការលើកឡើងនៅចំពោះមុខគ្នាដោយត្រង់ៗ និងប្រកបដោយការជឿទុកចិត្តគ្នា ហើយការដែលយើងកសាងបាននូវទំនុកចិត្តទៅវិញទៅមកជាមួយគ្នានៅក្នុងពេលនេះ គឺជាមូលដ្ឋានមួយដ៏សំខាន់នៅក្នុងឈានទៅរកការកសាងវប្បធម៌នៃការពិភាក្សាគ្នា។

ចំនុចមួយទៀតដែលខ្ញុំបាទសុំបញ្ជាក់ផងដែរ ក្នុងនាមខ្ញុំបាទជាជនបរទេសមួយរូបដែលបានមកធ្វើការនៅក្នុងស្រុកខ្មែរនេះដែលជាងបីមកឆ្នាំហើយ ខ្ញុំអរគុណណាស់ដែលបានឃើញនិងមានឱកាសរៀនសូត្រ នៅក្នុងការពិភាក្សាព្រឹកមិញនេះ ហើយឆ្លៀតនៅក្នុងឱកាសនេះក៏សូមថ្លែងអំណរគុណឯកឧត្តមអភិបាលរង ដែលបានអនុញ្ញាតិអោយ ខ្ញុំបាទបង្ហាញពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនដើម្បីឆ្លើយតបទៅនិងអ្វីដែលអស់លោក លោកស្រីបានលើកឡើងនៅក្នុងព្រឹកនេះ។

**ឯកឧត្តម ម៉ៃ ណាក់** ខ្ញុំសូមឯកភាពតាមមតិរបស់វាគ្មិទាំងអស់ដែលបានលើកឡើង ហើយមតិចុងក្រោយសំខាន់ដែលខ្ញុំចង់បានតើក្នុងឋានៈជាភ្ញៀវមានមតិយ៉ាងម៉េចនៅក្នុងការផ្ដល់នូវការពិភាក្សាសំរាប់យន្តការបង្ការទំនាស់នៅក្នុងការបោះឆ្នោតនៅក្នុងការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជានៅពេលនេះ ឃើញថាគាត់សរុបមកមានលក្ខណៈល្អ ជំរុញអោយយើងទាំងអស់គ្នាប្រកាន់នូវបញ្ហាអត់ធ្ងត់ដើម្បីយើងរួមគ្នាអនុវត្តនូវលទ្ធប្រជាធិតេយ្យអោយបានសមស្រប នេះហើយដែលយើងចង់បាន។ បញ្ហាមកដល់ពេលនេះគឺយើងសំដៅទៅលើការអត់ធ្មត់ជាទីបំផុត យើងមិនមមែនយកបញ្ហាដើម្បីបង្កើតហឹង្សានោះទេ អំពើរហឹង្សាកើតឡើងគឺជាភាពទន់ខ្សោយរបស់យើង សំដីទន់ភ្លន់រៀបសារឆ្លើយឆ្លងគ្នា ដូចលោកស្រីបានលើកការឆ្លើយដោយសមស្របទាំងអស់ ទាំងប៉ុន្មានចំនុចដែលវាគ្មិនបានលើកឡើងនេះគឺជាការឆ្លើយតបមួយតាមនីតិវិធីនៃការបោះឆ្នោត ឯវាគ្មិនមួយចំនួនចោទពីបញ្ហានេះបញ្ហានោះ នៅក្នុងនាមជាសមត្ថកិច្ចជាអ្នកទទួលខុសត្រូវនៅក្នុងការបោះឆ្នោតក៏យើងឆ្លើយតបដោយសុភាពរៀបសារ អ្វីដែលឆ្លើយមិនបានក៏យើងរក្សាទុកអ្វីដែលអាចឆ្លើយបានក៏យើងឆ្លើយដោយរៀបសារតាមស្មារតីការយល់ដឹងរបស់យើង យើងក៏អាចទទួលគ្នាបានដែរ អត់អីទេ។ តែបញ្ហាលើកពីបញ្ហានយោបាយនៅក្នុងការប្រជុំអី លើកក៏លើកទៅចុះ នេះធ្វើម៉េចបើគេចង់លើកទៅហើយ។ អំពីហឹង្សាដែលកើតមានឡើងនៅតាមសង្កាត់អីអញ្ចឹងយើងថា បញ្ហាបើកើតមានអញ្ចឹងទៅហើយយើងសំរួលកុំអោយមានទៅ បញ្ហាលើកផ្លាក់នោះបើមានយើងសំរួលកុំអោយមានទៅ ដើម្បីបង្កើតការយល់គ្នាទៅវិញទៅមកនៅក្នុងក្រុងប៉ៃលិនយើងទាំងមូលអោយយល់។ ហើយយើងធ្លាប់ធ្វើហើយការប្ដឹងតវ៉ាគ្នារហូតទៅដល់ គជប ដោះស្រាយបញ្ហាទំនាស់មិនចេញ រហូតដល់ក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយ ដូចវិវាទនៅកំពង់ធំ វិវាទនៅស្វាយរៀង វិវាទនៅភ្នំពេញ វិវាទនៅបន្ទាយមានជ័យ ចោទឡើងឥតឈប់ឈរ តាមខ្ញុំចាំនៅបន្ទាយមានជ័យអ្នកមានឈ្មោះបោះឆ្នោតរហូតដល់៣០០០នាក់នៅឃុំសង្កាត់មួយចំនួន ប៉ុន្តែបានមកបោះឆ្នោតបានតែ២០០០នាក់ ដល់អញ្ចឹងគណបក្សមួយចំនួនគាត់ប្ដឹង ដល់ប្ដឹងទៅដោះស្រាយយ៉ាងម៉េចចេញ ? ពេលដែលមកចុះឈ្មោះបោះឆ្នោតយើងដឹងទាំងអស់គ្នាហើយនៅពេលកម្មករទាំងអស់ទៅថៃវិញ តំបូងយើងអញ្ជើញកម្មករមកចុះឈ្មោះទាំងអស់ នេះគេហៅថាប្រតិភូអំណាចរបស់ឃុំសង្កាត់ដែលគេធ្វើយើងប្រគល់ប្រតិភូកម្មអំណាចអោយក្នុងគណៈកម្មាធិការបោះឆ្នោត ដល់ត្រឡប់ទៅវិញយើងមិនដឹងធ្វើម៉េចទេ ដល់ប្ដឹងទៅដោះស្រាយបញ្ហាអត់ចេញ នៅប៉ៃលិនក៏មានអញ្ចឹងដែរ នៅផ្សារព្រហ្ម ដូច្នេះយើងដោះស្រាយមិនចេញទេ។ មានតែទាំងអស់គ្នាពិភាក្សាគ្នាថា មូលហេតុមកពីប្រជាពលរដ្ឋផ្លាស់ទៅស្រុកកំណើតវិញ មូលហេតុមកពីប្រជាពលរដ្ឋផ្លាស់ទៅរកស៊ីនៅស្រុកថៃវិញ អញ្ចឹហើយបានជាខ្ញុំតែងតែនិយាយទទូចនូវលទ្ធិប្រជាធិតេយ្យដើម្បីអោយប្រជាពលរដ្ឋស្រលាញ់ចូលចិត្តចង់មកចុះឈ្មោះបោះឆ្នោតនិងមកបោះឆ្នោតទាំងអស់គ្នា។ ដូច្នេះត្រូវជំរុញអោយប្រជាពលរដ្ឋគាត់ភ្ញាក់រលឹក មកបោះឆ្នោត ដើម្បីជ្រើសរើសអ្នកដឹកនាំអំណាចដោយប្រជាពលរដ្ឋជាធំ នេះជាការពង្រឹងសន្តិភាពមួយដែលយើងចង់បានជាទីបំផុត។

បញ្ហាចុះផ្ដល់ប័ណ្ណព័តិមានយើងបានធ្វើហើយ នៅសល់ កន្លះខែទៀតនេះសូមអោយខាងក្រុមប្រឹក្សាសង្កាត់ក៏ដូចជាស្មៀនចុះរៀបចំយ៉ាងម៉េច អោយដល់ប្រធានភូមិប្រធានឃុំដើម្បីអោយ ប័ណ្ណព័តិមានបានដល់ប្រជាពលរដ្ឋ ហើយប័ណ្ណព័តិមានបានកែសំរួលហើយនៅក្នុងនោះទាំងអស់ សំរាប់ការចុះឈ្មោះបោះឆ្នោត និងការពិនិត្យបញ្ជីឈ្មោះបោះឆ្នោតនៅខែតុលាខាងមុខនេះ ពីថ្ងៃ០១ដល់ថ្ងៃ២០ខែតុលា ដូច្នេះយើងត្រៀមសំរាប់ការចុះឈ្មោះបោះឆ្នោត ទៀត ដូច្នេះឯកសារពេលនោះមានហើយគណៈកម្មាធិការឃុំសង្កាត់ពេលនោះនៅមានលេខាធិការដ្ឋានដដែរទេ មិនទាន់ទៅជា PEC នៅឡើយទេ ដូច្នេះគឺគេខំធ្វើតាមអ្វីដែល គជប បានរៀបចំអោយធ្វើតាមហ្នឹង។ ហើយអំពីអ្នកមានបញ្ជីឈ្មោះនោះគឺថា អំពីបច្ចុប្បន្ន ភាពបញ្ជីឈ្មោះពី គជប មកគ្នាខំពិនិត្យឡើងវិញទាំងអស់ហើយយកប័ណ្ណព័តិមាននោះទៅពិនិត្យនៅក្នុងហ្នឹង រៀបចំកែសម្រួលតាមហ្នឹង ការផ្លាស់ទីលំនៅប៉ុន្មានអ្នកមកក្នុងឃុំសង្កាត់នេះអ្នកមកថ្មីប៉ុន្មានអ្នក អ្នកដែលប្រតិភូអំណាចឃុំសង្កាត់ដែលបានដាក់អោយប្រាកដលំនៅដ្ឋានហ្នឹងត្រឹមត្រូវទេ ព្រោះក្នុងភូមិសង្កាត់

មួយៗយើងមានគណៈកម្មាធិការច្បាស់លាស់ ហើយក្រុមប្រឹក្សាសង្កាត់មួយចំនួន ក៏មាននៅក្នុងហ្នឹង ខាងគណបក្សមួយចំនួនក៏នៅរួមគ្នាក្នុងហ្នឹង ដូច្នេះយើងពិភាក្សាគ្នាធ្វើទៅអត់មានអ្វីដែលលំបាកទេ ហើយយើងជំរុញការងារហ្នឹងបាន។ យើងគិតថាការចុះឈ្មោះបោះឆ្នោតមានការលំបាកច្រើន ហើយស្មុគ្រស្មាញណាស់ អ្នកដែលចុះធ្វើបានដឹង ។ ហើយការផ្លាស់ប្តូរទីតាំងការិយាល័យបោះឆ្នោតនោះក៏សូមសំណូមពរអោយអង្គប្រជុំយើងពិនិត្យថា គួរត្រូវផ្លាស់ការិយាល័យបោះឆ្នោត កន្លែងណាដែលងាយស្រួល ដូច្នេះជម្រាបអោយហើយដើម្បីគណៈកម្មាធិការបោះឆ្នោតលោករៀបចំ ពីមុនយើងមាន៤៣មណ្ឌលឥឡូវ យើងអាចមាន៥០ ដូច្នេះការបោះឆ្នោតឆាប់ចប់ ពីសម័យអ៊ុនតាក់ការិយាល័យបោះឆ្នោតនិមួយៗអាច១០០០នាក់ ហើយឥឡូវក្នុងការិ យាល័យបោះឆ្នោតឆ្នាំ២០០៣យើងអោយច្រើនបំផុត៧០០នាក់ ហើយឥឡូវបន្ថែមការិយាល័យទៅទៀត ដូច្នេះអាចចំនួនបោះឆ្នោតក្នុងការិយាល័យនិមួយៗថយចុះ ហើយឆាប់ចប់ ដោយចាប់ផ្តើមពីម៉ោង៨ព្រឹកដល់ម៉ោង៣រសៀល។ បើករណីមានបញ្ហាកើតឡើង យើងយកមកពិភាក្សាលើតុទាំងអស់គ្នាទៅ ដើម្បីការជឿទុកចិត្តគ្នានិងមានតម្លាភាព។ ពេលបោះឆ្នោតឥឡូវនេះមានថែមមន្ត្រីម្នាក់ទៀតអោយជួយចាំមើលឈ្មោះ ពេលបោះឆ្នោតម្តងៗនៅតាមការិយាល័យបោះឆ្នោតដែលមានចំនួនច្រើន ដូចជានៅសង្កាត់ប៉ៃលិន សង្កាត់ស្ទឹងកាច់ អឺអញ្ចឹងជ្រួលច្របល់ណាស់ អ្នកខ្លះមិនចេះអក្សរពិបាករកឈ្មោះណាស់ ដូច្នេះមានថែមមន្ត្រីម្នាក់ទៀតអោយជួយចាំ រកឈ្មោះអោយហើយដើម្បីភាពងាយស្រួល។ ហើយម្យ៉ាងទៀត មនុស្សចាស់ និងខាងប្រដាប់អាវុធដែលត្រូវទៅយាមត្រូវតែបោះមុនគេ ហើយការិយាល័យនោះសូមអោយមានភាពទូលាយសមស្របទៅតាមស្តង់ដារផង ពិសេសគឺការពិនិត្យបញ្ជីឈ្មោះ ហើយពិនិត្យ បញ្ជីឈ្មោះជូនកាលអ្នកខ្លះមិនបានទៅពិនិត្យឈ្មោះទេ ដល់ពេលទៅបោះឆ្នោតទៅពិនិត្យឈ្មោះតែម្តង ដូច្នេះវាធ្វើអោយមានការលំបាកណាស់។ ឯការរាប់សន្លឹកឆ្នោតមិនពិបាកទេ តែកាលណារាប់ហើយគេមានចុះទៅតាមបែបបទរបស់គេ ដូចបែបបទ១១,០២,០៣អឺអញ្ចឹងគឺមានលទ្ធផលហើយនិងមានការចុះហត្ថលេខាទទួលស្គាល់លើលទ្ធផលហើយខ្ញុំឃើញគណបក្សទាំងអស់បានចុះហត្ថលេខាលើលទ្ធផលនៃការបោះឆ្នោតនៅប៉ៃលិនមិនសូវថាមិនចុះហត្ថលេខាទទួលស្គាល់លើលទ្ធផលទេ គឺចុះ តែបើនៅស្វាយរៀងគឺថាអត់ចុះហត្ថលេខាទទួលស្គាល់លើលទ្ធផលនៃការបោះឆ្នោតទេ មានការប្តឹងផ្តល់ ហើយកន្លែងខ្លះមានការចុះហត្ថលេខាទទួលស្គាល់លើលទ្ធផលបោះឆ្នោតហើយប៉ុន្តែក៏ចង់ប្តឹងទៀត តែដល់ប្តឹងគឺអត់មានត្រូវទេ ព្រោះយើងទទួលស្គាល់លើលទ្ធផលអស់ហើយ។ ខ្ញុំជឿថាអង្គប្រជុំ និងសមត្ថកិច្ចរបស់យើងនឹងជំរុញការងារនេះបានល្អ បើមានបញ្ហាកើតឡើងផ្សេងៗ គណបក្សនិមួយៗ ឬសមត្ថកិច្ចនិមួយៗ សរសេរជាលាយល័ក្ខអក្សរមក ព្រោះការលើកឡើងនៅពេលនេះមិនអស់គ្នាទេ ដោយសារពេលវេលាខ្លី ដូច្នេះសូមអោយសរសេរជាល័យល័ក្ខអក្សរមកដើម្បីជូនគណៈកម្មាធិការពិនិត្យរៀបចំដំណើរការអោយបានសមស្របបំផុត។

**លោក ឱក សេរី សោភក្តិ៍** ក្នុងឋានៈជាអ្នកសំរបសំរួលយន្តការឧប់សែលប្រ៉មនៅក្នុងទីក្រុងប៉ៃលិននេះ ខ្ញុំបាទគ្មានពាក្យអ្វីអោយសមនិងមនោសញ្ចេតនា កោតសរសើរដ៏ជ្រាលជ្រៅចំពោះអ្វីដែលបានស្តាប់ឮមកក្នុងមួយព្រឹកនេះទេ ទាំងខាងឯកឧត្តមអភិបាលរង ទាំងខាងលោកស្រី ទាំងខាងមន្ត្រីជំនាញ ទាំងខាងគណបក្ស និងសង្គមស៊ីវិលទាំងអស់ដែលបានមានប្រសាសន៏មក។